R. 6 17-2-62

ឆ្នាំទី ៣

លេខ ៥

# ទស្សនាវដ្ដី សាស្ត្រាចារ្យ

ផ្សាយចេញរាល់ត្រីមាស



ផ្សាយចេញ
ពីសមាគម សាស្ត្រាចារ្យ

ទីចាត់ការបណ្ដោះអាសន្ន
៦០,ផ្លូវអូរបូស្សី

ភ្នំពេញ

សមាគម
សាស្ត្រាចារ្យខ្មែរ
លេខ ១១
—o—

សូមក្រាបបង្គំទូលថ្វាយសម្ដេចព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងថ្ងៃបុណ្យខួបចំរើនព្រះជន្ម សម្ដេចជាទីគោរព ទាំង ជាទីស្នេហា សមាគមសាស្ត្រាចារ្យខ្មែរ សូមថ្វាយព្រះពរសព្ទសាធុការ សូមព្រះអង្គទ្រង់ប្រកបដោយសុភមង្គលយ៉ាងមនោរម្យ ទាំងដោយសុខភាពពេញបរិបូណ៌ ដើម្បីទ្រង់គង់នៅជាមគ្គុទ្ទេសក៍នៃប្រជាជាតិខ្មែរ អស់កាលជា-អវសាន ។

ទូលព្រះបង្គំទាំងឡាយជាសាស្ត្រាចារ្យ សូមសំដែងស្មារតីភក្ដីយ៉ាងជ្រាលជ្រៅចំពោះព្រះអង្គ ទាំង សូមប្ដេជ្ញារក្សាសាមគ្គីភាពយ៉ាងជិតស្និទ្ធជុំវិញព្រះអង្គ ដើម្បីសំរេចព្រះរាជបេសកកម្មទ្រទ្រង់ឯករាជ្យ អព្យាក្រឹត ទាំងស្វែងរកវឌ្ឍនភាព សន្តិភាព ជូនប្រទេសជាតិ ។

សូមព្រះរាជទានទូលថ្វាយនៅថ្ងៃទី ៣០ តុលា ១៩៦១

ជ– គណៈកម្មាធិការនាយក

ប្រធានសមាគមសាស្ត្រាចារ្យខ្មែរ,

កែ · សុខឆ

# មាតិការឿងៈ


កឋាមុខ សមតាមសេចក្ដីសង្ឃឹម . . . . . . . . . . . . . . ក

បិត្ត-គរុកោសល្យ -ការពិសោធន៍មួយនៅវិទ្យាល័យខ្មែរ អង់គ្លេស . . . . . . . ១

-អត្ថន័យរឿង ធនញ្ជ័យ . . . . . . . . . . . . . . . ៥

—le rôle de la géographie et ses méthodes . . . . . . . . . 7

ដំណឹងខ្លីៗ . . . . . . . . . . . . ៩

ជីវភាពមិត្តយើង -សំណូមពរខ្លះរបស់សាស្ត្រាចារ្យ. . . . . . . . . . . ១០

-ដំណឹងពីមិត្តយើង . . . . . . . . . . . . . . . ១២

-ការៈនៃមិត្តដំណាងសមាគមសាស្ត្រាចារ្យ . . . . . . . . . . ១៣

-កិច្ចការដែលគួរដឹង . . . . . . . . . . . . . . ១៥

វិទ្យាសាស្ត្រនិងសិល្បៈ -អំពីម៉ាស៊ីនដែលចេះគិត . . . . . . . . . . ១៧

-ទស្សនាភាពយន្តខ្មែរ . . . . . . . . . . . . . . . ២០

-បទភ្លេងនិងទំនុកច្រៀង (សុខន) . . . . . . . . . . . ២៥

ប្រអប់សំបុត្រ . . . . . . . . . . . . ២៦

-សេចក្ដីថ្លែងអំណរគុណពីមិត្តម្នាក់ចេញពីពេទ្យ . . . . . . . . . ២៧

-លិខិតរបស់សមាគមជូនទៅ ឯ.ឧ. ទេសរដ្ឋមន្ត្រីក្រសួងអប់រំនិងវិចិត្រសិល្ប . . ២៨

កីឡានិងល្បែង -តើយើងគប្បីហាត់ប្រាណឬទេ . . . . . . . . . . . . ២៩

ដំណើរទស្សនកិច្ច -នៃគណៈប្រតិភូសាស្ត្រាចារ្យខ្មែរនៅសាធារណរដ្ឋចិនប្រជាមានិត . . ៣១

មិត្តជ្រាបទេថា...—សាស្ត្រាចារ្យជំនាន់១៩៦០ខាតអស់ ៣ខែ ក្នុងការតែងតាំង . . . . . ៤៣

ជីវភាពមិត្តយើង -ស្នាដៃផ្ទាល់របស់សមាជិកនៅខេត្ត . . . . . . . . . . ៤៥

# កថាមុខ

## សមតាមសេចក្ដីសង្ឃឹម

ក្នុងឆ្នាំកន្លងទៅនេះ និស្សិតសាស្ត្រាចារ្យជាង២០០នាក់ បានទទួលឋានៈជាសាស្ត្រាចារ្យមធ្យមសិក្សាផ្នែកបឋមភូមិ ហើយបានចេញទៅកាន់មុខដំណែង នៅគ្រប់វិទ្យាល័យអនុវិទ្យាល័យតាមខេត្តនីមួយៗ ។ គួរសួរជាការឆ្ងល់ថា តើសាស្ត្រាចារ្យទាំងនោះ បានបង្ហាញសមត្ថភាពខ្លួនគ្រប់គ្រាន់ទេ ក្នុងការបង្ហាត់បង្រៀន? ពីព្រោះ ម្យ៉ាងរាជការនិងមហាជនខ្មែរមានសង្ឃឹមច្រើនថា សាស្ត្រាចារ្យជំនាន់ក្រោយៗនេះនឹងមានសមត្ថភាពគ្រប់គ្រាន់ សមតាមសេចក្ដីត្រូវការនៃសិក្សាធិការជាតិ ម្យ៉ាងទៀតបរទេសខ្លះ និយាយថារាជការបង្កើតសាស្ត្រាចារ្យរហ័សៗឲ្យរួចតែពីដៃ (formation au rabais) ដើម្បីដោះស្រាយការខ្វះខាតបុគ្គលិក ។

## តើការពិតយ៉ាងណា?

តាមការពិនិត្យស៊ើបសួររបស់យើង សាស្ត្រាចារ្យដែលចេញទៅបង្ហាត់ទាំងប៉ុន្មាន នៅគ្រប់វិទ្យាល័យអនុវិទ្យាល័យ បានបញ្ចេញសមត្ថភាពខ្លួនជាទីគាប់ចិត្តបិសក្យានុសិស្ស ។ មិត្តយើងជាច្រើន ដែលកាន់ដំណែងជាអធិការសាលាប្រាប់យើងថា កូនសិស្សដែលមកប្ដឹងសូមផ្លាស់សាស្ត្រាចារ្យ ក្នុងរឿងបង្រៀន ច្រើនតែសូមផ្លាស់សាស្ត្រាចារ្យបរទេស កម្រ សូមផ្លាស់សាស្ត្រាចារ្យខ្មែរណាស់ ។ មានសាស្ត្រាចារ្យខ្មែរច្រើននាក់ ល្បីល្បាញខាងការប៉ិនប្រសប់បង្រៀន (ដែលមិត្តយើងស្គាល់ខ្លះទៅហើយ) រហូតដល់សិស្សថ្នាក់ខ្ពស់ៗ ទាមទារដកសាស្ត្រាចារ្យបរទេសដែលមានបរិញ្ញាបត្រ (licence) ចេញ ហើយសូមយកសាស្ត្រាចារ្យខ្មែរពីបឋមភូមិទៅបង្រៀនជំនួសវិញ ។

មតិសិស្សគេថាសាស្ត្រាចារ្យខ្មែរ បង្រៀនងាយយល់ស្ដាប់បាន គេឃើញថាមានការប្រឹងប្រែងច្រើន ហើយមានការស្និទ្ធស្នាលច្រើនផង ។ សិស្សហ៊ានសាកសួរនឹងពិភាក្សាជាមួយ ជាភាសាជាតិទាល់តែយល់សិន ទើបកត់ទុកក្នុងសៀវភៅជាភាសាបារាំង!! ។ ជាមួយនឹងគ្រូបរទេស សិស្សប៉ះទង្គិចជារឿយៗ ជួនកាលគេមិនឲ្យសួរគេ ជួនកាលគេបន្តុះបង្អាប់នាំឲ្យតូចចិត្តជាខ្លាំង ។

លទ្ធផលនេះ មិនមានអ្វីគួរឲ្យយើងឆ្ងល់ទេ ធម្មជាតិប្រាប់ថាខ្មែរបង្រៀនខ្មែរគ្នាឯង វាតោងតែស៊ីសំរុងគ្នាជាងគេ ។ សាស្ត្រាចារ្យខ្មែរយើង គ្រាន់បើជាងសាស្ត្រាចារ្យបរទេស ត្រង់យើង

យល់ចិត្តថ្មីមយុវជនខ្មែរផងគេ គ្រន់តែយើងមានស្មារតីយល់ថាយើងកសាងអនាគតឲ្យយុវជនជាប្រយោជន៍ប្រទេសជាតិយើង ។ យើងមិនគិតតែស្វែងប្រាក់ផាក់ហោប៉ៅកាលណា? ។ ដូច្នេះហើយ ទោះចំណេះទូទៅរបស់យើងខ្វះខាតបន្តិចបន្តួច (មែនទែនយើងចាញ់តែចំណេះសាស្ត្រាចារ្យបរទេសដែលមាន licence ប៉ុណ្ណោះទេ) យើងខំស្រាវជ្រាវខ្លួនឯងថែមទៀត ហើយយើងចេះប៉ុន្មានយើងបានពីពោះឲ្យសិស្សទាំងអស់គ្មានសល់ទេ ។ ពេលវិស្សមកាល យើងខំឃ្មឹងស្មាធិប្រជុំគ្នារៀនបង្កើនសមត្ថភាពខ្លួនថែមទៀត ។ ពេលប្រឡងឌីប្លូមលើកទី ២ យើងសុខចិត្តនឿយជាងគេឥតត្អូញត្អែរ ចំណែកឯសាស្ត្រាចារ្យបរទេសខ្លះទៅសំពកលេងឯស្រុកគេយ៉ាងព្រងើយ មិនរវល់ទាំងគោរពសេចក្ដីបញ្ញត្តិរដ្ឋការយើងផងដែលតំរូវឲ្យគេត្រឡប់មកស្រុកខ្មែរវិញ មុនពេលប្រឡងលើកទី ២ ។ សាស្ត្រាចារ្យបរទេសខ្លះ សាលាបើកទ្វារចូលរៀន ពីរអាទិត្យហើយ ក៏មិនទាន់មកដល់ទីកន្លែងផង ។

ការធៀបប្រៀបប៉ុណ្ណេះបង្ហាញឲ្យឃើញច្បាស់ថាការរិះគន់សមត្ថភាពសាស្ត្រាចារ្យខ្មែរ មិនសមហេតុសមផលទេ, នៅមានអ្នកខ្លះចង់ថា បានជាកំរិតចំណេះកូនខ្មែរអន់ មកពីសាស្ត្រាចារ្យខ្មែរអន់ ។ និយាយយ៉ាងនេះខុសស្រឡះ ។ ឧទាហរណ៍មួយ អធិការបារាំងម្នាក់មក ពីស្រុកបារាំងបានទៅអង្គុយស្ដាប់សាស្ត្រាចារ្យខ្មែរម្នាក់បង្រៀននៅកំពង់ចាម គាត់មានសេចក្ដីស្ញើចសរសើរពន់ពេក ហើយសាស្ត្រាចារ្យនោះ មានចំណេះត្រឹមឌីប្លូមប៉ុណ្ណោះ ។ បុព្វហេតុ ដែលនាំឲ្យសិស្សខ្សោយក្នុងមុខវិជ្ជាខ្លះមានច្រើនយ៉ាង យើងពុំអាចវែកញែកក្នុងទំព័រនេះបានទេ ។ ប៉ុន្តែសូមកុំបន្ទោសសមត្ថភាពសាស្ត្រាចារ្យខ្មែរ ព្រោះគ្នារៀបចំសំរាប់តែបង្រៀនក្នុងបឋមភូមិទេចំនួនគ្នាក៏នៅតិច ហើយខ្លះជាប់ទៅធ្វើជាចាងហ្វាងវិទ្យាល័យអនុវិទ្យាល័យអស់ទៅទៀត ។

តទៅអនាគត រាជរដ្ឋាភិបាលយើងនឹងបង្កើតឲ្យបានសាស្ត្រាចារ្យកាន់តែច្រើន ហើយប្រកបដោយសមត្ថភាពកាន់តែខ្ពស់ទៀត ។ សាស្ត្រាចារ្យដែលនៅរាជធានីសុទ្ធតែធ្លៀតឱកាសរៀននៅមហាវិទ្យាល័យ ដើម្បីយកបរិញ្ញាបត្រ បង្កើនចំណេះវិជ្ជាខ្លួន ។

ទោះជាយ៉ាងណាក៏ដោយក៏ការពិសោធន៍បានបង្ហាញថា សាស្ត្រាចារ្យខ្មែរយើងបានបំពេញការងារខ្លួនគួរជាកិត្តិយសណាស់ សមតាមសេចក្ដីសង្ឃឹមពិត ។

# វិជ្ជា-គរុកោសល្យ



## ការពិសោធន៍មួយ នៅវិទ្យាល័យខ្មែរអង់គ្លេស

ដោយលោក ព្រំ សង្កា

ដើម្បីកុំឲ្យសិស្សនិយាយគ្នាចូលក្នុងថ្នាក់ ក្នុងពេលដែលខ្ញុំរវល់សរសេរ ឬ អានសាកពបរផ្សេងៗ ខ្ញុំបានប្រើរបៀបដូចតទៅ ៖

សូមលោកអ្នកជ្រាបថា ខ្ញុំបង្រៀននៅថ្នាក់ទី ៨ នៃវិទ្យាល័យខ្មែរអង់គ្លេស ដែលមានសិស្សអាយុចន្លោះ ១០ឆ្នាំ ទឹង ១២ឆ្នាំ ។

ថ្នាក់ខ្ញុំនេះ មានតុសិស្សរៀបជា ៧ ជួរទឹងសិស្សចំនួន ៤៤ នាក់ ។ នៅជួរនិមួយៗខ្ញុំឲ្យសិស្សបោះឆ្នោតរើសសិស្សម្នាក់ក្នុងជួររបស់ខ្លួនធ្វើជានាយជួរ ។ បាននាយជួរហើយ ខ្ញុំឲ្យនាយជួរទាំងនេះ បោះឆ្នោតរើសសិស្សម្នាក់ទៀត ធ្វើជាដំណាងថ្នាក់របស់ខ្លួនទាំងអស់គ្នា ។

នាយជួរ មានភារៈកត់ឈ្មោះកូនជួររបស់ខ្លួនដែលនិយាយក្នុងពេលរៀន ។ ដំណាងថ្នាក់មានភារៈកត់ឈ្មោះសិស្សទាំងអស់ ទាំងនាយជួរទាំងកូនជួរនៅក្នុងថ្នាក់ពេលគ្រូមិននៅ ទឹងពេលកំពុងរៀនដែរ ។

រីឯសិស្សទាំងឡាយដែលជាកូនជួរ ក៏មានភារៈកត់ឈ្មោះនាយជួរនៃជួររបស់ខ្លួនដែរ បើនាយជួរនេះនិយាយលេង ។

ចំពោះសិស្សជាតំណាងថ្នាក់ ត្រូវនាយជួរនិងកូនជួរទាំងអស់កត់ឈ្មោះវិញ នៅពេលណា ខ្លួនធ្វើខុសដូចគ្នាដែរៗ រួមសេចក្ដីទៅឃើញថាម្នាក់ៗមានភារៈត្រួតមើលការស្ងប់ស្ងាត់ក្នុងថ្នាក់គ្រប់ៗគ្នា ។

មុននឹងចាប់បោះឆ្នោតរើសនាយជួរនិងតំណាងសិស្ស ខ្ញុំសួរសិស្សទាំងអស់ថា ៖

ទាងចង់ចេះអង់គ្លេសឬទេ ?

ឆ្លើយឡើងអ៊ូថា ៖ ចង់ (សូមនិយាយថា ចង់ណាស់លោកគ្រូ) ខ្ញុំសួរទៀត ៖ ដូច្នោះត្រូវធ្វើយ៉ាងម៉េច ?

សិតសេខៀន ឆ្លើយភ្លាមមុនខ្ញុំហៅថា ៖ ត្រូវខំរៀន ត្រូវស្ដាប់លោកគ្រូ ។

ដួនឡូនថា : ត្រូវចាំរៀននៅផ្ទះ ។ សិស្សផ្សេងៗទៀតក៏ឆ្លើយដូចៗគ្នា ពោះបើអ្នកដែលខ្ញុំសង្កេតឃើញថាខ្ជិលនោះក៏ដោយ ។

ខ្ញុំថា : «នាងទាំងអស់គ្នាសុទ្ធតែនិយាយត្រូវ ខ្ញុំសប្បាយចិត្តណាស់ ។ តែនាងនៅខ្វះចំណុចមួយទៀត ដែលនាងទាំងអស់គ្នាត្រូវធ្វើដើម្បីចាប់ចេះអង់គ្លេស ។

– បាទអត់ទេ ។

បន្ទាប់មកបន្តិចនាយជួរម្នាក់យកកូនក្រដាសមកឲ្យខ្ញុំទៀត ។ មើលទៅឃើញ « គៀតសុវណ្ណនិយាយ »

– ឥឡូវគៀតសុវណ្ណទៀតហើយ ។ ម៉េចចេះតែនិយាយឲ្យគេកត់ឈ្មោះ ។

– ចា៎ ខ្ញុំអត់ទេ ។

អ្នកអង្គុយជិតខាងថា "គ្មានទេ និយាយតានៗ"

– ខ្ញុំថា មើល៍ នរណាដឹងឮ?

អ្នកជិតខាងទាំងអស់លើកដៃស្របគ្នាថាដឹងឮ ។

– ចុះគៀតសុវណ្ណថាយ៉ាងម៉េចទៅបើអញ្ចឹង ។ តើយើងនិយាយមែនឬទេ ? ប្រាប់ឲ្យត្រង់មក គ្មាននរណាវាយដំអ្វីទេ ។ មើលសុផលគេហ៊ានប្រាប់ហ៊ានទទួលខុសត្រូវ ។

– ចា៎ ខ្ញុំគ្រាន់តែ. . . . ។

– ខ្ញុំថា " ដល់គ្រាន់តែទៀតហើយ ។ ចូរឈប់គ្រាន់តែ . . . នេះទៅ " ។

មួយអាទិត្យកន្លងមក ខ្ញុំសង្កេតឃើញថាថ្នាក់បានស្ងាត់ជាងមុន ប៉ុន្តែក្រដាសកត់ឈ្មោះ ក៏ខ្ញុំនៅបានទទួលច្រើនណាស់ដែរ ។

នៅដើមអាទិត្យបន្ទាប់មក ខ្ញុំប្រាប់សិស្សទាំងអស់ថា :-

– ក្រដាសដែលកត់ឈ្មោះនេះមិនឥតប្រយោជន៍ទេ ដល់ពីរអាទិត្យទៀត ខ្ញុំនឹងរើសក្រដាសនោះមករាប់មើលឈ្មោះឲ្យដឹងថានរណាមាត់ច្រើនជាងគេ ។ ចូរនាងទាំងអស់ខំប្រណាំងគ្នា ឲ្យបានអត់ជាប់ឈ្មោះទាំងអស់គ្នា ។ ពេលនោះទើបថ្នាក់យើងបានល្អជាងគេ» ។

មួយអាទិត្យកន្លងទៅខ្ញុំបានឃើញថាក្រដាសកត់ឈ្មោះមានចំនួនតិចជាងមុន ។ មួយអាទិត្យ-ទៀតកន្លងទៅ ចំនួនក្រដាសកត់ឈ្មោះក៏ថយចុះទៀត ។ នៅពេលរើឈ្មោះអ្នកមាត់មើលហើយរាប់ចំនួនសព្វគ្រប់ហើយ ខ្ញុំក៏ប្រកាសប្រាប់នូវលទ្ធផល ។ ខ្ញុំនិយាយលើកទឹកចិត្តអ្នកដែលមិនមាត់ក្នុងពេលរៀន នឹងពន្យល់ដល់កុមារឬកុមារីដែលមាត់ ចាប់តាំងពីលេខមួយមក អំពីផលអាក្រក់ដែលកើតមកអំពីការមាត់ក្នុងថ្នាក់ ។ ខ្ញុំឲ្យសិស្ស

មាត់ទាំងនេះឡើងនិយាយម្ដងម្នាក់ៗ ។ គេសុទ្ធតែសន្យាថា ឈប់និយាយឲ្យដាច់ ឈ្លោះដូចពេលមុនទៀត ។ ខ្ញុំចាំសង្កេតមើលៈ.... ។

ម្ដងនោះខ្ញុំងើបមើលទៅឃើញប៊ុនធឿន កំពុងខ្វែងដៃធ្វើជាសញ្ញាកាកបាទ ។

ខ្ញុំនឹកក្នុងចិត្តអាណិតផង ចង់សើចផង ប៊ុនធឿនធ្វើអ្វីហ្នឹង?

បាទខ្ទួនឡើងចង់និយាយរកខ្ញុំ ខ្ញុំខ្វែងដៃថាមិនហ៊ាននិយាយទេ ។ ខ្ញុំប្រាប់ទៅសិស្សដទៃ “នាងភល់គ្នាឃើញទេ ប៊ុនធឿនធ្វើតាមវិន័យណាស់ ប៊ុនធឿនគេជៀសមិនមាត់ព្រោះគេគិតឃើញថាត្រូវគោរពនាងទាំងអស់ដែលកំពុងរៀន” ។

ខ្ញុំធ្វើយ៉ាងដូច្នេះរៀងរហូតមក ។ លទ្ធផលបានគួរជាទីពេញចិត្ត ។ ខ្ញុំលែងលំបាកនឹងត្រូវកុំឲ្យសិស្សនិយាយដូចមុនទៀតហើយ ។ បើខ្ញុំមិននៅក្នុងថ្នាក់ ឬខ្ញុំរវល់មើលសាកបរ ឬរវល់សរសេរអ្វីបន្តិចបន្តួច ក៏ខ្ញុំឥតព្រួយខ្លាចសិស្សប្រឡែងឡូឡាក្នុងថ្នាក់ដែរ ។

នៅថ្ងៃសុក្រ១៩ ខែកញ្ញា ខ្ញុំបានកែក្រដាសគត់ឈ្មោះសិស្សមាត់ក្នុងថ្នាក់មករាប់មើលដូចមុន ។ ខ្ញុំឃើញដូចតទៅៈ

អ្នកដែលលេខ១ខាងមាត់ក្នុងពីរអាទិត្យដែលកន្លងមក មានចំនួនតែម្នាក់ ហើយបានមាត់តែចំ-នួន៦ដង ។

អ្នកលេខ២ មាត់៥ដង មានចំនួន៣នាក់ ។

អ្នកលេខ៣ មាត់៤ដង មានចំនួន៤នាក់ ។

អ្នកលេខ៤ មាត់៣ដង មានចំនួន៣នាក់ ។

អ្នកលេខ៥ មាត់២ដង មានចំនួន៩នាក់ ។

បូករួមទាំងអស់ ឃើញសិស្សចំនួន ២០នាក់ ដែលបានមាត់ក្នុងសិស្សទាំងអស់៤៤នាក់ ហើយក្នុងពីរអាទិត្យ ។ ចំណុចអ្វី? នរណាដឹង? (គ្មាននរណាដឹង តែហាក់ដូចជាចំគិតគ្រប់ ៗ គ្នា) ខ្ញុំឲ្យសិស្សម្នាក់យកសៀវភៅទៅអាន រួចខ្ញុំឲ្យសិស្ស ៣·៤ នាក់និយាយគ្នាអ៊ូ ខ្ញុំសួរទៅសិស្សមួយចំណែកទៀតថាៈ “នាងខាងណោះស្ដាប់បានឬទេ?” ។

កុមារម្នាក់ឆ្លើយថាៈ“អត់បានទេលោកគ្រូ” ។

– ដូច្នោះចំណុចអ្វី? នរណាដឹង ?

សំភាគឡើងឈរដោយញញឹមរៀបនឹងឆ្លើយ ។

សូមថា “ខ្ញុំលោកគ្រូ ៗ ”

– សូមចំណុចអ្វី?

សូម “ត្រូវកុំនិយាយក្នុងថ្នាក់„

– ខ្ញុំថា „សូមនិយាយត្រូវ ។ ដូច្នោះយើងទាំងអស់គ្នាសុខចិត្តធ្វើយ៉ាងនេះឬទេ?” ។

លើកដៃឲ្យ ប្រុង ទាំងខឹល, ទាំងខ្សឹល ឆ្លើយថា "សុខ" ។

ខ្ញុំថា "ខ្ញុំសប្បាយចិត្តណាស់ ។ ខ្ញុំជឿជាក់ថានាងមុខជាចេះអង់គ្លេសយ៉ាងចំណានមិនខាន" ។ រួចក៏ខ្ញុំនិយាយប្រាប់សិស្សទាំងអស់អំពីហេតុផលដែលបោះឆ្នោតអម្បាញ់មិញ ព្រមទាំងភារៈនៃនាយជួរ, កូនជួរនិងសិស្សតំណាងថ្នាក់ ។ ខ្ញុំបន្ថែមទៀតថា

– បើ មិត្តនាងកត់ឈ្មោះនាង គឺមិត្តនោះគ្រាន់តែធ្វើតាម សំដីរបស់យើងទាំងអស់គ្នាដែលថាកុំ-ឲ្យនិយាយក្នុងពេលបង្រៀននោះតែប៉ុណ្ណោះ ។ បើមិនកត់ដូច្នេះ រួចផល់នាងខ្លះ មិនប្រព្រឹត្តតាមសំដីខាងលើទៅ នោះនាងទាំងអស់គ្នាលើកដៃឆ្លើយថា ។ សុខចិត្តមិននិយាយ? ធ្វើអ្វី ។

របៀបនេះគឺជាប់អនុវត្តភ្លាម ។ ៥នាទីក្រោយមក នាយជួរទី១រត់ត្រែមកតុខ្ញុំ កាន់ក្រដាសតូចមួយមកផង ។ ក្នុងក្រដាសនោះដាក់ថា "សុផលនិយាយ" ។ ខ្ញុំសើចភ្លាមព្រោះវារហ័សពេកហើយថា

– សុផលម៉េចក៏និយាយ? ឥឡូវគេកត់ឈ្មោះហើយ ។ សុផលឯងសុខចិត្តឲ្យគេកត់ឬទេ? ។

– បាទ, បាទ ខ្ញុំគ្រាន់តែសុំខ្ចីដៃខ្មៅគេ ។

– ខ្ញុំសួរអ្នកអង្គុយជិតខាងថាបានឮឬទេ ។ ឆ្លើយថាឮ ។

– ខ្ញុំថាដូច្នោះ សុផលឯងខុសហើយ ក្រោយៗកុំខ្ញុំគ្រាន់តែ...ទៀត ព្រោះបើច្រើនគ្នាគ្រាន់តែខ្ញុំគ្រាន់តែៗ នៅមិនអ៊ូក្នុងថ្នាក់នៅហើយ! ។

– សុផលឯងមានអ្វីជំទាស់ឬទេ? ។

# អត្ថន័យ   ទាក់ទងរឿង ( ធនញ្ជ័យ )

( ក្នុងកម្មវិធីសិក្សាថ្នាក់ទី ៦ ទំនើប )

រឿងព្រេង ជារឿងដែលប្រជាជននិទានតៗគ្នាពីមាត់មួយទៅមាត់មួយពោល គឺ ជារឿងប្រជាមានិត ដែលអ្នកនិពន្ធព្រេងនាយបានប្រឌិតឡើងប្រហែលក្នុងសម័យលង្វែកឧត្តុង្គ ( សម័យរុងរឿងនៃអក្សរសាស្ត្រខ្មែរ ) ។

រឿងព្រេង ជារឿងជឿនលឿនស្ថិតនៅលើសច្ចៈ បែបមនុស្សនិយម ។

គួរកត់សំគាល់ថា រឿងព្រេងមានការៈសំខាន់ ៖

១ - និទានកំសាន្ត - សប្បាយ

២ - ប្រដៅទូន្មាន - អប់រំ ឲ្យមានការភ្ញាក់រលឹក ។

គោលមតិរបស់រឿងប្រជាមានិតមានច្រើន ។ រឿង " ធនញ្ជ័យ " ជារឿងមួយនៃរឿងព្រេងទាំងឡាយ បាននាំឲ្យយើងស្គាល់អាថ៌កំបាំងដូចតទៅនេះ ៖

១ - ជំនឿ·ទំនៀមទម្លាប់ : មានក្បួនហោរាជាដើម ។ យាយប្រពន្ធហោរាទាយឲ្យម្តាយធនញ្ជ័យថា „ កូនកើតមកទំនឹងខ្ញុំគេ „ ។ បើយើងពិនិត្យទៅ ការទាយនេះ គឺគ្រាន់តែជា ហើយការជានេះ យោលទាំងស្រុងទៅនឹងស្ថានភាពគ្រួសារធនញ្ជ័យ ទៅនឹងការរស់នៅរបស់រាស្ត្រសាមញ្ញក្នុងសម័យនោះ ។ ជំនឿនេះបានបង្កើតនូវមតិមួយថា „ កូននៅហោរ „ ។

២ - ជីវភាពមនុស្សៈ សម័យធនញ្ជ័យ សង្គមមនុស្ស បែកជាវណ្ណៈ មានរាស្ត្រសាមញ្ញ, មន្ត្រី-សេដ្ឋី- មហាក្សត្រិយ៍... ។ ដំណើររឿងសោត តាំងពីដើមដល់ចប់ បានបង្ហាញជាក់ស្តែងនូវសកម្មភាពទំនឹងឥទ្ធិពលនៃវណ្ណៈរៀងៗខ្លួន ។

៣ - របបរស់នៅៈ សម័យព្រេងនាយនោះ ប្រទេសខ្មែរ ស្ថិតនៅក្រោមរបបសក្តិភូមិ ។ នាម៉ឺនមន្ត្រីជិះជាន់សង្កត់សង្កិន ប្រជារាស្ត្រតាមទំនើងចិត្ត ។ រាស្ត្រត្រូវចាត់ទុកជាបាវព្រាវ, ខ្ញុំកញ្ជះគេ ។

ជាពិសេស រឿងធនញ្ជ័យបញ្ចាំងយ៉ាងច្បាស់នូវរបបកុដុម្ពិកៈមានសេដ្ឋីជាតួតំណាងសការៈនេះឯង,

៤– ការឆាត់ឆន្ទៈរាជមហាក្សត្រិយ៍និងប្រជារាស្ត្រ៖ តាមផ្លូវជឿនសម័យធនញ្ជ័យ ព្រះរាជាមានអំណាចទូលំទូលាយ ហើយទ្រង់សព្វព្រះរាជហឫទ័យ ល្បងបញ្ញាប្រជារាស្ត្រដែលមានខធនញ្ជ័យជាតួយ៉ាង ។

៥– បញ្ញានៃមនុស្ស៖ បញ្ញានាំឲ្យមានជ័យជំនះ ។ ឥទ្ធិពលនៃបញ្ញាបាននាំឲ្យធនញ្ជ័យឈ្នះការព្យាបាទគ្រប់យ៉ាង មានការព្យាបាទរបស់សេដ្ឋី-នាម៉ឺន ជាដើម ។

ម្យ៉ាងទៀត បញ្ញាធនញ្ជ័យបានធ្វើឲ្យប្រទេសខ្មែរមានកិត្តិស័ព្ទ កិត្តិនាមល្បីល្បាញ ជាច្រើនលើកដោយមានជ័យជំនះលើបរទេស មានប្រទេសចិន-ជាដើម ។

– យោបល់រួម៖ រឿងធនញ្ជ័យបង្ហាញនូវគំនិតប្រឆាំងនឹងរបបគ្រប់គ្រង-ការអប់រំអយុត្តិធម៌ក្នុងសម័យបុរាណនោះ ។ គំនិតជឿនលឿននេះជាបុព្វហេតុនៃលទ្ធិប្រជាធិបតេយ្យបែបបច្ចុប្បន្ននេះឯង ។

សេចក្តីបញ្ចប់៖ មតិណែនាំសង្ខេបៗខាងលើនេះ ពុំមែនជាអត្ថាធិប្បាយទូលំទូលាយឡើយ គឺគ្រាន់តែជាគំនិតមួយដ៏ស្តួចស្តើងប៉ុណ្ណោះទេ ។ សូមមិត្តអ្នកអានមេត្តាពិចារណាវិនិច្ឆ័យតាមផ្លូវជឿនផងចុះ ។

ព្រហ្ម-ឈួន-ជុល

# LE ROLE DE LA GEOGRAPHIE ET SES METHODES

La géographie ne vise pas à former des géographes. Son rôle essentiel est d'intéresser les élèves, de les instruire sans doute, mais surtout de former leur intelligence par la géographie. Laissons à l'enseignement supérieur le soin de produire des spécialistes, soit en vue de renseignement soit pour la recherche.

Or, pour atteindre son objet aux niveaux, qui nous intéressent (niveaux de l'enseignement secondaire et primaire) la géographie doit être bien comprise et enseignée selon des méthodes modernes. Le contenu des programmes a souvent bien peu d'importance. Chaque pays ou même chaque province le fixe selon ses besoins. Ce qui compte, c'est d'avoir de bons pédagogues. Pour nous en convaincre, évoquons avec M. Clozier, la classe de géographie et tout le matériel qu'elle met en œuvre : la carte murale toujours présente, l'appareil à projections, les photographies assemblées sur un panneau, le professeur, la craie à la main, toujours prêt à tracer au tableau noir un croquis, un schéma, un graphique, sans parler des activités extrascolaires (excursions, visites d'usines, etc.. ). Cette discipline requiert la plus ample documentation, en même temps qu'elle est, pour les élèves, la source d'informations la plus riche. C'est pourquoi le professeur (au niveau secondaire du moins) doit se tenir au courant des progrès de la science géographique, des transformations économiques et politiques du monde — seul moyen, pour lui, de conserver cet esprit de synthèse vivante qui est la pierre de touche de la géographie, de saisir les interprétations successives des phénomènes physiques, d'enregistrer les étapes de l'évolution des unités économiques dans leur localisation. Face aux élèves, le maître doit élaguer, aérer, décanter, éliminer l'accessoire pour s'en tenir à l'essentiel, éviter, en outre, le dogmatisme — attitude des débutants ou des maîtres routiniers. La géographie ne résout pas les problèmes présentés aux élèves, mais propose des solutions de plus en plus approchées ou vraisemblables. Les élèves sont alors dans une position d'attente pour accueillir les données sans cesse renouvelées. Le professeur crée en eux l'inquiétude de savoir, base essentielle de toute pédagogie.

Dans la plupart des pays, ces instructions pédagogiques accompagnent les programmes. On peut les résumer comme suit, à toutes fins pratiques :

### 1. — L'exposé géographique

Inutile de rechercher la leçon-type de géographie. S'il joue bien son rôle d'éveilleur d'intelligences, le vrai professeur a recours à de multiples procédés. Chaque maître possède un acquis et un tempérament propres ; ses auditoires sont étonnamment fluides et variables d'une année à l'autre. Les procédés usuels sont de deux sortes : l'exposé-conférence, qu'il faut se garder de rendre dogmatique, et la leçon-causerie. Celle-ci associe les élèves à l'élaboration du cours, surtout quand il s'agit de jeunes élèves ; c'est un exposé en commun, s'effectuant selon l'ordre voulu par le maître, de manière à être constructif dans l'esprit des enfants.

### 2. — Le croquis, l'illustration, la carte

Choses nécessaires pour éviter que l'enseignement ne soit livresque. Le succès de ce procédé dépend de la compétence du maître et de l'effort personnel de l'élève, dont la curiosité est tenue en éveil par les images qu'on lui présente ou par des allusions ou des comparaisons empruntées à son expérience quotidienne. Cartes, images, moulages, plans en relief, autres documents, tous ces procédés sont indispensables pour matérialiser la description du maître et rendre plus persuasive sa démonstration. A défaut de projections, le maître dessinera un croquis au tableau afin de pallier l'insuffisance des cartes murales, ou de cartographier plus exactement le sujet de la leçon. La carte complète le croquis, mais encore faut-il que l'élève soit entraîné à la lire et à l'analyser. Même remarque pour les photographies ou projections, qu'on doit commenter afin que les élèves sachent les regarder, afin qu'ils les comprennent. Ces divers procédés excercent la mémoire visuelle des élèves et peuvent tenir lieu de résumé

### 3. — Le rôle du manuel

Le meilleur enseignement est oral ; le manuel ne peut le remplacer, mais il complète l'exposé. C'est un instrument de travail commun au maître et à l'élève : il aide à illustrer la leçon par ses cartes et ses images, il sert à faire aux élèves des exercices et des lectures utiles. Il faut bien se garder d'utiliser tels quels les questionnaires ou exercices tout préparés que proposent certains manuels. C'est au professeur d'établir quels devoirs doivent faire les élèves, selon la matière étudiée en classe, et les points sur lesquels leur attention doit être attirée. Tâche peu facile pour le maître, mais qui révèle sa compétence et dont dépend le succès des élèves.

### 4. — Les excursions

Pour apprendre aux élèves à observer par eux-mêmes les phénomènes qu'enseigne la géographie, les excursions, promenades en ville et à la campagne, les visites d'usines, de gares, de fermes, etc., sont indispensables, et, lorsqu'on le veut vraiment, moins difficiles à organiser qu'on ne le pense trop souvent.

Encore faut-il bien les préparer, comme toute autre leçon. Quelle joie pour un vrai maître d'ouvrir l'esprit des enfants au sens de l'observation, de transposer dans la réalité ambiante les notions apprises en classe, de leur montrer qu'il n'existe pas de barrière entre l'enseignement et la vie. Il a le choix entre deux méthodes sur le terrain : ou bien, à chaque arrêt, faire observer et donner aussitôt les explications, ou bien faire observer et poser les problèmes d'abord, puis fournir ses explications à la fin de la promenade.

Nous résumerons toute notre pensée en disant que, pour qu'il soit fructueux, l'enseignement de la géographie doit être fait d'une manière intelligente par des maîtres qu iaient le souci d'une large culture géographique, qui sachent s'adapter au niveau de leur auditoire scolaire. S'ils se bornaient à transposer un manuel, ils s'abaisseraient au rang de répétiteurs. Mêmes des procédés théoriquement insuffisants peuvent donner de bons résultats, s'ils sont mis en œuvre avec une conviction active et réfléchie ; médiocre, au contraire, est l'efficacité d'une tâche contrainte et forcée. Les instructions officielles sont faites pour libérer le professeur, non pour gêner initiative.

## អំពីប្រឡងឌីប្លូម

តាមសេចក្ដីសំរេចរបស់ឧត្ដមប្រឹក្សាសិក្សាធិការឆ្នាំនេះ ឌីប្លូមប្រឡងគ្មានវិញ្ញាសាសួរមាត់ទទេទេ វិញ្ញាសាទាំងអស់ត្រូវធ្វើជាសរសេរវិញ ។

មជ្ឈដ្ឋានសាស្ត្រាចារ្យ ពេញចិត្តនឹងវិធានការណ៍នេះដែរ ពីព្រោះវានាំឲ្យរៀបចំការប្រឡងងាយបន្តិចហើយឆាប់ផង ។ ជាពិសេស សិស្សដែលនៅខេត្រក្រៅមិនបាច់ចាយប្រាក់មកប្រឡងឯភ្នំពេញដូចឆ្នាំមុនៗទៀត ពីព្រោះមានបង្កើតទីប្រឡងនៅទីរួមខេត្រធំៗដូចបាត់ដំបង សៀមរាប កំពង់ចាម កំពត ស្រាប់ៗ ។

វិញ្ញាសាសរសេរទាំងអស់គ្មានសួរក៏អាចឲ្យវិនិច្ឆ័យដំរេះសិស្សបានដូចគ្នា ។ ប៉ុន្តែគួរប្រយ័ត្នមែនទែនកុំឲ្យបេក្ខជនលួចចំឡងគ្នាបាន កុំគប្បីមានអធ្យាស្រ័យត្រង់កន្លែងនេះឲ្យសោះ ។

## បានអាន

នៅក្នុងAnnales de la Faculté de droit ក្បាលទី ៣ ដែលទើបនឹងចេញផ្សាយ យើងចាប់អារម្មណ៍ជាខ្លាំងលើអត្ថបទ របស់សាស្ត្រាចារ្យបារាំងឈ្មោះ ឡាំងតាំង (Lintingre) ។

ក្នុងអត្ថបទនេះ អ្នកនិពន្ធនិយាយពីការរីកចំរើននៃសិក្សាធិការជាតិយើង ដោយសំអាងទៅលើស្ថិតិដែលគាត់បានប្រមូល ប៉ុន្តែគាត់ឆ្លៀតឱកាសនេះ លាតត្រដាងអំពីជំនួយបារាំងខាងផ្លូវវប្បធម៌គ្រប់យ៉ាង ។ នេះជាការធម្មតាទេ បើគាត់ចង់លើកតម្កើងពលស្រុកគាត់ ឲ្យឃើញមានបុព្វការគុណអស្ចារ្យមកលើខ្មែរយើង ។

ប៉ុន្តែ លោកឡាំងតាំងឆ្លៀតឱកាសនេះឆ្កឹះឆ្កៀលអំពីរឿងភាសា គាត់លើកនេះ ដាក់នោះ ហាក់ដូចជាចង់ចាប់ខ្មែរប្រជល់នឹងខ្មែរ ដោយប្រើឃ្លាសើកសៀតបញ្ចិតបញ្ចៀង ។ តើគាត់មានគោលបំណងយ៉ាងណា? ជនបរទេសនេះត្រូវការអ្វីមកវីវក្នុងរឿងខ្មែរ ? ។

សូមបញ្ជាក់ថា លោកឡាំងតាំងនេះ មិនមែនធ្វើតែសាស្ត្រាចារ្យទេ គាត់មានសរសេរកាសែតញយៗ ហើយទាក់ទងគ្រប់មជ្ឈដ្ឋាន តាំងតែពីព្រះសង្ឃទៅ ។ ប្រហែលជាដោយសកម្មភាពមិនស្រួលខ្លះ បានជាគាត់ត្រូវផ្លាស់ចេញពីស្រុកខ្មែរ ។ ឮថាគេបញ្ជូនគាត់ទៅស្រុកអាហ្វ្រិកៗ សាធុ សាធុ ទៅចុះ ! ។

# ជីវភាពគ្រូយើង

## សំណូមពរខ្លះរបស់សាស្ត្រាចារ្យ

នៅពេលចូលរៀនឆ្នាំសិក្សានេះ អ្នកគ្រូ លោកគ្រូជាច្រើននៅខេត្តក្រៅបានសរសេរសំបុត្រ ឬ សាកសួរដោយផ្ទាល់មកសមាគមយើង ឲ្យជួយដោះស្រាយ អំពីការផ្លាស់ប្តូរចេញពីខេត្រមួយទៅ ទៅខេត្រមួយទៀត នឹងអំពីការប្រឡងចូលវិទ្យាស្ថានជាតិគរុកោសល្យ ផ្នែកសាស្ត្រាចារ្យ ។

មតិដែលយើងបានដកស្រង់មក មានដូចតទៅនេះ :.

ក- ការផ្លាស់ប្តូរ:

១– តាមព័ត៌មានមកថា លោកគ្រូ-អ្នកគ្រូ ដែលធ្លាប់បង្រៀននៅមធ្យមសិក្សា ៣ឬ៤ឆ្នាំ មកហើយក៏ដោយ, បើកាលណាសុំផ្លាស់ចេញពីខេត្រមួយទៅខេត្តមួយទៀតនោះកជការក៏អនុញ្ញាតតាមពាក្យសុំ តែអាចជំរូវទំលាក់ទៅបង្រៀននៅបឋមសិក្សាវិញបាន ។

២– មានលោកគ្រូ អ្នកគ្រូខ្លះទៀត ធ្លាប់បង្រៀននៅសាលាបឋមសិក្សានោះត្រូវកជការហៅបញ្ចូលឲ្យទៅបង្រៀននៅមធ្យមសិក្សាវិញដែរ ។

ចំពោះរឿងនេះ អ្នកគ្រូ-លោកគ្រូខ្លះសប្បាយចិត្ត· អ្នកគ្រូ-លោកគ្រូខ្លះទៀតក៏អាក់អន់ចិត្ត ផុតសេចក្តីសង្ឃឹម ។ ចំណែកយើង យើងសូមប្រសិទ្ធិពរ ជូនអ្នកគ្រូ-លោកគ្រូដែលទើបនឹងផ្លាស់ពីបឋមសិក្សាមក សូមឲ្យលោកបានជ័យជំនះក្នុងការបង្ហាត់កូនខ្មែរ ទៅតាមផ្លូវចំរើនគ្រប់ផ្នែកដើម្បីចំរើនឧត្តមគតិ វឌ្ឍនធម៌ ។ តែរឿងម្យ៉ាងទៀតដែលគួរឲ្យយើងសោកស្តាយបំផុត គឺការផ្លាស់លោកគ្រូ - អ្នកគ្រូពីមធ្យមសិក្សាមកបឋមសិក្សាវិញនេះ ។

បើនិយាយពីការពិសោធន៍ នឹងសមត្ថភាពក្នុងការបង្រៀន គួរទុកលោកគ្រូ អ្នកគ្រូដែលធ្លាប់បង្រៀននៅមធ្យមសិក្សានេះនៅដដែល ទោះបីមានការផ្លាស់ប្តូរចេញពីវិទ្យាល័យ ឬអនុវិទ្យាល័យណាក៏ដោយ ព្រោះបញ្ហាខ្វះសាស្ត្រាចារ្យនៅមធ្យមសិក្សានៃប្រទេសខ្មែរ តែងតែមានចោទនៅឡើយ។ ដូចនេះ យើងសូមធ្វើសំណូមពរដល់ក្រសួងដែលមានសមត្ថកិច្ចមេត្តាលៃលកទុកលោកគ្រូ - អ្នកគ្រូ,

ទាំងនេះឲ្យបង្រៀននៅមធ្យមសិក្សាវិញ ព្រោះការពិសោធន៍ និងសមត្ថភាពរបស់លោកទាំងអស់នោះក៏មានបរិបូណ៌ ដើម្បីធ្វើឲ្យការសិក្សានៅមធ្យមសិក្សាបានចំរើនដែរ ។

១- ការប្រឡងប្រជែងចូល

វិទ្យាស្ថានជាតិគរុកោសល្យ:

លោកគ្រូ-អ្នកគ្រូជាច្រើនឆ្ងល់ហើយឆ្ងល់ទៀតថា ហេតុអ្វីបានជាឆ្នាំនេះ រាជការមិនអនុញ្ញាតឲ្យលោកគ្រូ-អ្នកគ្រូណាដែលបានធ្វើការគ្រប់ឆ្នាំសិក្សាហើយ ប្រឡងចូលវិទ្យាស្ថានជាតិគរុកោសល្យហើយហេតុដូចម្ដេចបានជាឆ្នាំទៅ រាជការអនុញ្ញាតឲ្យលោកគ្រូ-អ្នកគ្រូប្រឡងប្រជែងចូលបាន? ។

អក័ត្វឆ្នាំនេះ មុនថ្ងៃប្រឡងមួយថ្ងៃ ទើបរាជការចេញសេចក្ដីប្រកាស មិនឲ្យលោកគ្រូ-អ្នកគ្រូណាធ្វើការមិនទាន់គ្រប់ ៣ ឆ្នាំប្រឡង ។ ហេតុផនជ្រួលច្របល់ ព្រោះមិនយល់នូវគំនិតនៃសេចក្ដីប្រកាស ។ អ្នកទាំងអស់គ្នាកើតព្រួយបារម្ភសៅហ្មងចិត្តយ៉ាងខ្លាំង ។ មតិផ្សេងៗផុសចេញមកៗ អ្នកខ្លះនិយាយថា បើគិតតាមឆ្នាំសិក្សា ហើយប្រឡងនៅពេលមហាវិស្សមកាលផងទៀត នោះគ្មានទាស់ខុសអ្វីទេ ពីព្រោះដល់ពេលចូលរៀនគ្រប់ល្មម ។ អ្នកខ្លះទៀតយល់ថា បើរង់ចាំមួយឆ្នាំទៀត នោះឡើងដល់ទៅបួនឆ្នាំ រាប់ផុតពីកំរិតរាជការកំណត់បីឆ្នាំទៅហើយ ។

ក្នុងយោបល់នេះ យើងសូមធ្វើសំណូមពរដល់ក្រសួងមានសមត្ថកិច្ចគិតគូរយ៉ាងណា ឲ្យលោកគ្រូ-អ្នកគ្រូដែលធ្វើការគ្រប់បីឆ្នាំសិក្សាហើយ បានចូលប្រឡងប្រជែង ដូចជាសម័យប្រឡងឆ្នាំ ១៩៦០ ផង ។

សមាគមសាស្ត្រាចារ្យខ្មែរ

# ដំណឹងពីមិត្តយើង

យើងមានសេចក្ដីរីករាយ នឹងជូនដំណឹងដល់មិត្តយើងថា :

- កាលពីថ្ងៃ ១៤-៨-៦១ នេះ គណៈប្រតិភូសាស្ត្រាចារ្យខ្មែរមួយដែលមានលោកឈរតីមហុន មាសខិម ទេសសាកាវុទ្ធិ កែបផន អ្នកស្រីជិនវ៉ែន បានចេញដំណើរទៅសហរដ្ឋអាមេរិក ដើម្បីសិក្សាពីកម្មវិធី និងពីអភិបាលសាលាមធ្យមសិក្សា ។
- កាលពីថ្ងៃ ១៧-៩-៦១ លោកឌួងសារិនបានចេញដំណើរទៅប្រទេសបារាំង សិក្សាអំពីការអភិបាលអនុវិទ្យាល័យនិងវិទ្យាល័យ ។
- លោក ម៉ៃ លន់ និងឌុច ផាន់ បានទៅរួមប្រជុំសន្និសីទនៅជប៉ុន ម្នាក់ស្ដីពីស្ថិតិ អ្នកទីពីរស្ដីពីការស្រាវជ្រាវខាងសង្គមកិច្ចនៅអាស៊ីអាគ្នេយ៍ ។
- លោក ភឹង គុន បានអញ្ជើញត្រឡប់មកពីប្រទេសបារាំងដល់ភ្នំពេញវិញហើយ ។ សព្វថ្ងៃលោកកាន់ដំណែងជានាយកឧត្ដមសិក្សា ។
- លោក ព្រាប ប៊ឹន បានត្រឡប់មកដល់ភ្នំពេញវិញ ពីថ្ងៃ ៩-៩-៦១ ក្រោយពីបានបំពេញបេសកកម្មមួយឆ្នាំនៅប្រទេសបារាំង ។ សព្វថ្ងៃលោកកាន់ដំណែងជាអគ្គលេខាធិការនៅមហាវិទ្យាល័យអក្សរសាស្ត្រ ។
- លោក ឡឹក វ៉ន ជាហិរញ្ញិក សមាគមយើង ទើបតែនឹងបានបុត្រីយ៉ាងប្រណិត ដែលទើបនឹងកើតនៅពេលថ្មីៗនេះ ។ សមាគមសូមសរសើរដល់បិតាមានភ័ព្វថ្មីនេះ ។

ជួយផ្សាយ ទស្សនាវដ្ដី "សាស្ត្រាចារ្យ"

គឺ ជួយពង្រីក សមាគម របស់មិត្ត ។

# ភារៈនៃមិត្តជំណាងសមាគមសាស្ត្រាចារ្យ

បើមិត្តចង់ជួយ ឲ្យសមាគមយើង "ដើរ"

មិត្តធ្វើយ៉ាងនេះ ។

ឆ្លៀតពេលទំនេរខ្លះ ដើម្បី ៖

១-ចែកទស្សនាវដ្ដី



២- ហៅមិត្តឯទៀតៗ ប្រជុំពីកិច្ចការសិក្សានៅតំបន់



៣-ប្រមូលភាគទាន ពីរខែម្ដង ហើយ ផ្ញើអាណត្តិ តាមប្រៃសណីយ៍ទៅហិរញ្ញិក



៤- ជួយលក់ទស្សនាវដ្ដី



៥- ទទួលប័ណ្ណ ពីសមាជិកចូលថ្មី



៦- រំលឹកពីអត្ថបទ ដែលមិត្តម្នាក់ ភ្លេចសរសេរ



៧- ផ្ញើពត៌មានទៅគណៈ

កម្មាធិការនាយក



៨- ស្ទាក់ដំណឹងកុំឲ្យគេបរួច



៩- ធ្វៀតពេលប្រជុំសាស្ត្រាចារ្យ

ដើម្បីសួរពីសុខទុក្ខសមាជិក



១០- ពឹងពាក់មិត្តឯទៀត

ឲ្យជួយការងារម្តងៗ



បំពោះ អត្តបទ ដែលមិត្តសរសេរហើយក្តី

បំពោះ ទស្សនាវដ្តី ដែលមិត្ត មិនទាន់បាន ទទួលក្តី

និងបំពោះ សំបុត្រស្នាម ផ្សេងៗ ទៀតក្តី

សូមផ្ញើមកទាក់ទង នឹង

លោក ឡឹក . វ៉ន សាស្ត្រាចារ្យ វិទ្យាល័យ ស៊ីសុវត្ថិ ៗ

# កិច្ចការដែលគួរដឹង

សំនួរ : តើរដ្ឋបាលស្រុក - ឃុំអាចបញ្ជូនដំណាងទៅសង្កេតការណ៍ ក្នុងទីប្រជុំប្រឹក្សាសាស្ត្រាចារ្យ ឬទីប្រជុំប្រឹក្សាវិន័យនៃសាលាឬទេ ? ។

ឆ្លើយ : តាមច្បាប់ផ្ទៃក្នុង (règlement intérieur) ដែលប្រើប្រាស់ក្នុងវិទ្យាល័យ នៃព្រះរាជាណាចក្រ ក្រុមប្រឹក្សាសាស្ត្រាចារ្យមានសមាសភាពរួមតែ ចាងហ្វាង សិក្សាធិរក្ស អគ្គានុរក្ស និងសាស្ត្រាចារ្យគ្រប់ថ្នាក់ទាំងអស់ រីឯក្រុមប្រឹក្សាវិន័យ ក៏មានតែ ចាងហ្វាង សិក្សាធិរក្ស អគ្គានុរក្ស និង សាស្ត្រាចារ្យពីរបីនាក់ ដែលបានជ្រើសតាំងជាសមាជិក ។ គ្មាននាក់ណាក្រៅសាលាមកចូលរួមប្រជុំបានឡើយ។ បញ្ហានេះជាបញ្ហា ស្វ័យភាព នៃកិច្ចការសិក្សា ក្នុងបរិវេណសាលានីមួយៗ ។

ប៉ុន្តែ ចាងហ្វាងសាលាមានភារៈ និងទាក់ទងនឹងរដ្ឋបាលស្រុកឃុំ ចំពោះការងារទូទៅ ដូចជាការសង់សាលា ការហត្ថកម្មលើកផ្លូវលំ ការចាក់ថ្នាំបង្ការរោគ ការងារយុវជន . ។ល។ រដ្ឋបាលស្រុកឃុំ និង ឪពុកម្តាយសិស្សអាចចូលរួមប្រជុំតាមចិត្តជាមួយចាងហ្វាង និង សាស្ត្រាចារ្យក្នុងអង្គការ ដូចជាសមាគមពង្រីកសិក្សា ឬ សមាគមកីឡា ដែលមានសកម្មភាពរីកចេញក្រៅបរិវេណសាលា ។

សំនួរ : សាស្ត្រាចារ្យខ្លះដែលទៅកាន់ដំណែងជាចាងហ្វាងនៅអនុវិទ្យាល័យថ្មីៗ បានប្រទះនឹងការលំបាកខ្លាំង ដោយខ្វះសម្ភារៈគ្រប់យ៉ាង តុកៅអី ក្តារខៀន ដីស សៀវភៅមើល ផែនទី ...។ជួនកាលរត់ទៅខ្ចីពីសាលាបឋមសិក្សា ហើយរល់តែគេតាមមកទារវិញព្រឹកល្ងាចៗ ។ តើដោះស្រាយយ៉ាងណា ?

ឆ្លើយ : វិធានការមុនដំបូង គួរទាក់ទងក្រសួងអប់រំជាតិឲ្យគេដោះស្រាយឲ្យ ដោយបន្ទាន់ ។ ជាពិសេស សូមបញ្ជាក់ឲ្យគេបំរុងថវិកាសំរាប់សាលាខ្លួន បានគ្រប់គ្រាន់ ហើយតាមសួរឲ្យមែនទែនប្រយ័ត្នមានការភ្លេចភ្លាំង ។ បើក្នុងឆ្នាំសិក្សានេះ គ្មានថវិកាបំរុងពីមុនសំរាប់សាលា

ទេ ដោយសាលាកើតក្រោយពេលបំរុងថវិកា គេនៅតែខ្វះខ្វងសូមឲ្យរកការដោះស្រាយដោយមធ្យោបាយណាទាល់តែបាន ពីព្រោះតែអនុវិទ្យាល័យបើកទ្វារហើយ ឲ្យបានហ្វាងគ្នាខ្លះខ្វងម្នាក់ឯង (ជួនកាលមិនទាន់តាំងបើកប្រាក់ខែផង) នោះ គ្នាមុខជា "ទាល់គំនិតហើយ" ។

វិធានការមួយទៀតក្រៅផ្លូវការ បានហ្វាងគួរទៅទាក់ទងនឹង រដ្ឋបាលស្រុក-ខែត្រ ទាក់ទងនឹងឪពុកម្ដាយសិស្សអ្នកស្រុក ទាក់ទងសមាគមពង្រីកសិក្សា បើមាន ឲ្យគេជួយជាអំណោយគ្រប់យ៉ាង ក្រែងដោះស្រាយបានខ្លះ ។

សំណួរ - សមាគម មានសមាជិកប៉ុន្មានហើយ មកដល់ពេលសព្វថ្ងៃនេះ ?

ចម្លើយ – សមាគមយើងមានសមាជិក ៤៦០នាក់ហើយ ។ គួរមិត្តរីករាយ នឹងសរសើរដល់មិត្តទាំងឡាយ ដែលបានទំអំពាវនាវផ្ដល់សមាជិកថ្មីឲ្យសមាគម ។

## សូមមិត្ត ជួយឧបត្ថម្ភ

ទស្សនាវដ្ដី "សាស្ត្រាចារ្យ" យើង

– ដោយជួយជាវ នឹងជួយផ្សាយឲ្យគេជាវ

– ដោយជួយអត្ថបទផ្សេង ៗ

– ដោយជួយដាស់តឿន នឹងតិះតៀន



# វិទ្យាសាស្ត្រ និង [illegible]

## អំពីម៉ាស៊ីនដែលចេះគិត

អស់មិត្តសាស្ត្រាចារ្យប្រហែលជាធ្លាប់បានឮ គេនិយាយអំពីម៉ាស៊ីនអេឡិចត្រូនិកសំរាប់គិតលេខ ដែលបារាំងហៅថា calculatrices électroniques ។ ម៉ាស៊ីនបែបនេះអាចជំនួសមនុស្សច្រើននាក់ ក្នុងការគិតលេខ ហើយធ្វើលេខក្នុងពេលយ៉ាងខ្លីបំផុត ។ ឧបមាដូចជាការគិតលេខ ដែលជំរូវឲ្យអ្នកប្រាជ្ញជាច្រើនក្រុមអង្គុយធ្វើអស់ពេលច្រើនឆ្នាំ ម៉ាស៊ីនអេឡិចត្រូនិកយកមកគិតតែក្នុងពីរបីវិនាទីជាការស្រេចហើយគ្មានកាន់ច្រឡំទៀតផង ។

ប៉ុន្តែបើម៉ាស៊ីនបែបនេះប្រើបានត្រឹមតែគិតលេខជំនួសមនុស្ស យើងមិនជាស្ងើចប៉ុន្មានទេ ។ តែឥឡូវ គេប្រើម៉ាស៊ីនទាំងនេះឲ្យបកប្រែពីភាសាមួយទៅភាសាមួយ ដូចជាប្រែពីភាសាអង់គ្លេសទៅភាសារុស្ស៊ី ឬប្រែច្រាសមកវិញជាដើម ។ ម៉ាស៊ីន នេះនិយាយឬសរសេរត្រូវតាមច្បាប់វេយ្យាករណ៍នៃភាសានីមួយៗឥតខ្ចោះ ហើយសព្វថ្ងៃម៉ាស៊ីនមួយអាចបកប្រែបានប្រហែល ៤០០០ពាក្យក្នុងមួយនាទី គិតទៅវាបកប្រែរហ័សជាងមនុស្សឆ្ងាយណាស់ ។

មិនតែប៉ុណ្ណោះ គេប្រើម៉ាស៊ីនបែបនេះឲ្យ "អាន" ឯកសារពីសម័យបុរាណ ដូចជាអក្សរចារឹកជាវប្បធម៌របស់សង្គម មនុស្សដែលសាបសូន្យជាច្រើនពាន់ឆ្នាំទៅហើយជាដើម ។ ឥឡូវនេះ គេ «បង្រៀន» ម៉ាស៊ីនទាំងនេះ ឲ្យចេះអានអក្សរភ្លេង ចេះតែងបទភ្លេង ចេះលេងអុកចត្រង្គជាមួយមនុស្ស ។ គេប្រើវារៀបវចនានុក្រមក៏បាន គឺប្រើឲ្យវាកត់ចំណាំពាក្យ ឬសេចក្ដីឯកសារទុកច្រើនប៉ុន្មានក៏បាន វាមិនចេះភ្លេចទេ ហើយបើគេសួរចំ វាឆ្លើយប្រាប់មួយរំពេចឥតបាច់ស្រាវជ្រាវនឹកយូរទេ ។

លទ្ធផលយ៉ាងនេះ អស្ចារ្យពេក ស្ទើរតែមិន

ហ៊ានជឿផង ។ សូមជំរាបថា ម៉ាស៊ីនដែលធ្វើការជំនួសខួរក្បាលមនុស្សបែបនេះ មានប្រើប្រាស់ពិតប្រាកដក្នុងលោកយើងសព្វថ្ងៃនេះ ។ គ្រឿងគ្រៅសរសៃសសួងដែលផ្សំបានជាម៉ាស៊ីននេះ ប្រទាក់ប្រទងគ្នាប្រហែលតែនឹងសរសៃវិញ្ញាណនៃខួរក្បាលមនុស្សដែរ ។ កាលពីដើមដំបូង ផ្ទះថ្មួនប្រាំជាន់ ដាក់គ្រឿងម៉ាស៊ីនតែមួយស្ទើរតែមិនអស់ ប៉ុន្តែសម័យឥឡូវ ដោយសារគេចេះប្រើគ្រង់ស៊ីស្ទ័រ ( transistors de germanium ou de silicium) តូចៗល្អិត ជំនួសអំពូលវិទ្យុធំៗ ម៉ាស៊ីនជាន់ថ្មីមានទំហំប៉ុនទូប៉ុណ្ណោះ ហើយស៊ីក-ឡាំងអគ្គីសនីតិចបផង ។

បើនិយាយឲ្យងាយយល់ពីរបៀបប្រើម៉ាស៊ីន "ចេះគិត" នេះ យើងសូមជំរាបយ៉ាងខ្លីដូចតទៅ ។ ម៉ាស៊ីននេះស្តាប់នឹងយល់បញ្ហាបាន លុះត្រាតែគេប្រែបំណោទដែលវាត្រូវដោះស្រាយជាសញ្ញាតាមក្បួន ( signaux codifiés ) តាមចំណាំរបស់វាសិន ។ គេចៀសវាងមិនប្រើសញ្ញាច្រើនតួទេ ជួនកាលគេប្រើតែសញ្ញា ២ តួ មានលេខ ១ នឹងលេខសូន្យជាដើម ។ ឧបមាគេចង់បកប្រែកំណាព្យមួយជាភាសាដទៃ គេត្រូវកែអក្សរទាំងអស់ទៅជាលេខ១ នឹងលេខសូន្យចំរុះគ្នា ធ្វើយ៉ាងនេះសិន ទើបម៉ាស៊ីន "យល់" ។ លុះគេដាក់ប្រធានជាសញ្ញាបែបនេះក្នុងម៉ាស៊ីនហើយ គេត្រូវកំណត់កម្មវិធី ឲ្យម៉ាស៊ីនដឹងរបៀបដំណើរដោះស្រាយទៀត ។ ឧទាហរណ៍គេកំណត់កម្មវិធីឲ្យម៉ាស៊ីនមានទំនងយ៉ាងនេះ «ឯងត្រូវគុណចំនួននេះ នឹងចំនួននេះ ឃើញប៉ុន្មានយកទៅដកនឹងចំនួននោះ ហើយឯងត្រូវកត់លទ្ធផលទុក ។ រួចឯងយកចំនួនមួយទៀតចែកនឹងប្រាំ ឃើញប៉ុន្មានយកទៅបូកនឹងចំនួនដែលបានកត់ទុកពីមុន ។ ជាទីបញ្ចប់ ឯងប្រាប់លទ្ធផលមកអញ!» ។ ម៉ាស៊ីនឆ្លើយមកវិញសុទ្ធតែសញ្ញា១ នឹងសូន្យ; ម្ចាស់ត្រូវបកស្រាយមកជាភាសាមនុស្សសាមញ្ញវិញទើបគេយល់ ។ ម៉ាស៊ីនដើរឯក គឺម៉ាស៊ីនដែលធ្វើការទាំង ៣ មុខ (បកប្រែប្រធានជាសញ្ញា, អនុវត្តកម្មវិធី, បកប្រែលទ្ធផល) ដោយខ្លួនឯងបានមិនរំពឹងជំនួយពីមនុស្ស ។

មិត្តយើងអាចលាន់មាត់ថា ម៉ាស៊ីននេះគ្មានអ្វីជាអស្ចារ្យទេ ពីព្រោះមនុស្សដាក់កម្មវិធីប្រាប់ផ្លូវមុនអស់ទៅហើយ ។ ឆ្លើយថាពិតដូច្នោះមែន ប៉ុន្តែម្ចាស់វាអាចបង្គាប់ឲ្យវាចំណាំវិធី ដោះស្រាយចំណោទរាប់ពាន់យ៉ាង ឲ្យវាចំណាំក្បួនវេយ្យាករណ៍ច្រើនភាសា ហើយវាមិនចេះភ្លេចឬច្រឡំក្បួនបាន

ទេ ។ ដល់ពេលធ្វើការ ម្ចាស់គ្រាន់តែប្រាប់វាឲ្យដោះស្រាយចំណោទតាមវិធីនេះៗ ឬ តាមក្បួនវេយ្យាករណ៍ភាសានេះៗ ជាការស្រេច ។ សព្វថ្ងៃនេះ ម៉ាស៊ីនខ្លះចេះ «ត្រិះរិះរកហេតុផល» (opérations de logique) ដែលជាបើគេចោទបញ្ហាបែបនេះមក ត្រូវប្រើវិធីនេះៗដោះស្រាយទើបសមហេតុសមផលជាងវិធីដទៃទៀត ។ យ៉ាងណាមិញ ក្នុងការបង្រៀនម៉ាស៊ីនឲ្យចេះលេងអុកចត្រង្គ ម្ចាស់វាពន្យល់ក្បួនល្បែងឲ្យវាដឹងថា គោលដើរយ៉ាងនេះ សេះដើរយ៉ាងនេះ នាងដើរយ៉ាងនេះ ស្តេចដើរយ៉ាងនេះ ។ល។ ប៉ុន្តែលេងមួយក្តាដំបូង ម៉ាស៊ីនច្បាស់ជាលេងចាញ់ម្ចាស់វា ថ្វីបើវាចេះក្បួនល្បែងហើយក្តី ។ ខណៈនោះម្ចាស់ប្រាប់វាថា បើ។ញលេងស្មៀតនេះទៅ ឯងលេងស្មៀតនោះមកទើបដោះគុនរួច ។ លុះលេងបាន ៥០-៦០ក្តា ម៉ាស៊ីនចំណាំការពិសោធន៍បានកាន់តែច្រើន ម្ចាស់ក៏ក្បាត់ស្មៀតចាញ់ម៉ាស៊ីនវិញម្តងៗ ។ លុះលេងបានមួយពាន់ មួយម៉ឺនក្តាម៉ាស៊ីនចេះទប់ទល់បានគ្រប់ស្មៀតទាំងអស់ ពេលនោះម្ចាស់វាលេងចាញ់រហូត ។ គិតសព្វៗទៅ វិជ្ជាដែលរៀនខាងប្រើឲ្យម៉ាស៊ីនគិតគូរជំនួសមនុស្ស ដែលបារាំងហៅថា la cybernétique ប្រើវិធីដូចគ្នានឹងសាស្ត្រាចារ្យយើងដែរ គឺ ទំលាប់ឲ្យសិស្សចំណាំបានច្រើនសិន ទើបទំលាប់ឲ្យត្រិះរិះពិចារណា ផ្គូផ្គងជាក្រោយ ។

បើដូច្នេះ តទៅថ្ងៃមុខ យើងគួរចាត់ទុកថា មនុស្សអាចធ្វើម៉ាស៊ីនមានប្រាជ្ញាជាងខួរក្បាលខ្លួន ឬយ៉ាងណា?។ ត្រង់នេះយើងសូមឆ្លើយថា មនុស្សអាចសាងម៉ាស៊ីនដែលកាន់តែពូកែសក្តិសិទ្ធ អាចជួយខ្លួនក្នុងសកម្មភាពផ្សេងៗនឹងពិបាកៗបាន ។ ប៉ុន្តែតាំងពីអតីតកាលមក យើងមិនដែលឃើញប្រដាប់ប្រដាដែលធ្វើដោយដៃមនុស្ស ជំនួសមនុស្សបានគ្រប់ជំពូកទាំងអស់ទេ ។ ទោះជាយ៉ាងណាក៏ មនុស្សនៅតែមើលខុសត្រូវ ដឹកនាំម៉ាស៊ីនអេឡិចត្រូនិកគ្រាន់តែជួយមនុស្សក្នុងការត្រិះរិះគិតគូរផ្នែកខ្លះៗ ដើម្បីបំណេញពេលកម្លាំងនឹងបំណេញពេល ប៉ុន្តែវាពុំអាចមានសតិសម្បជញ្ញមាន មនោសញ្ចេតនាផុសឡើងឯងៗ ដូចខួរក្បាលមនុស្សបានឡើយ ។

# ទស្សនា ភាពយន្តខ្មែរ

## សារៈសំខាន់នៃភាពយន្ត

យើងមិនបាច់បង្អាតពេលឲ្យយូរ ដើម្បីវែកញែកនិងរាប់រៀបពីសារៈសំខាន់នៃភាពយន្ត ក្នុងការកសាងនិងលំអវប្បធម៌ជាតិ និងក្នុងការអប់រំមហាជនទេ ។ សារៈសំខាន់នេះមានជាក់ស្ដែងណាស់ ជាពិសេសគឺក្នុងការអប់រំយុវជន ។

យើងគ្រាន់តែទាញសម្បជញ្ញៈមិត្តសាស្ត្រាចារ្យយើងថា ក្នុងសតវត្សទី២០ យើងនេះភាពយន្តជាមែកធាងមួយយ៉ាងសំខាន់ ឬសំខាន់បំផុតផង ក្នុងចំណោមមែកធាងសំខាន់ៗ ទាំងឡាយនៃវប្បធម៌ ។ នេះព្រោះថា ភាពយន្តមានឱកាស មានទីកន្លែង មានលក្ខណសម្បត្តិចាំបាច់គ្រប់គ្រាន់ សំរាប់ក្ដាប់អ្នកទស្សនា ។ ហើយម្យ៉ាងទៀត តាមបង្អាក់នៃអារ្យធម៌បច្ចុប្បន្ន ភាពយន្តជាមធ្យោបាយលំហែមួយ ដែលបានគេនិយមជាងគេ(មិននិយាយពីវិទ្យុទូរទស្សន៍) ហើយប្រមូលបានមហាជនកកុះករជាងគេទៀត ។

បើភាពយន្តហើយ មានលក្ខណៈល្អស្រស់បំព្រង នោះរស្មីនៃវប្បធម៌ក៏ភ្លឺតាមនោះ ឯកំរិតវប្បធម៌នៃមហាជន ក៏ឡើងតាមនោះដែរ ។ ហើយនៅក្រៅប្រទេសវិញ នោះការស្គាល់ និងការទទួលស្គាល់តម្លៃនិងខ្លឹមសារនៃប្រទេសជាតិយើងពីសំណាក់ជនបរទេស ក៏មានល្បឿនទៅតាមនោះមួយភាគទៀត ។ តែបើភាពយន្តហើយ ផ្ដេសផ្ដាសអាក់សែ ពុករលួយកាប់ចាក់ នោះមហាជនពិសេសគឺយុវជន ក៏ទោរទន់ស្រើបស្រាលទៅតាមនោះមួយកំរិតដែរ ។ តាមពិតយុវជនកំពុងឋិតនៅក្នុងវ័យពាលក ហើយនិងវ័យវីរបុរសនិយម ដែលចូលចិត្តណាស់ខាងកំរើក, ចលនាវិញ្ញាណបសាទទាំងប្រាំរបស់ខ្លួន ។ រួចហើយនៅក្រៅប្រទេសវិញ នោះគេវាយតម្លៃយើងខុសស្រឡះតែម្ដង ។

## លក្ខណៈភាពយន្ត

ដោយយកចិត្តទុកដាក់ជាខ្លាំង ទៅលើសារៈសំខាន់និងឥទ្ធិពលដែលភាពយន្តបានជះទៅលើមហាជននេះ ហើយដោយមានបំណងចង់ផ្ដល់វិភាគទានខ្លះដល់ភាពយន្តខ្មែរយើង ដែលទើបនឹងប៉ុចពន្លកឡើងនេះ យើងសូមឲ្យមតិខ្លះ ចំពោះរឿងដែលបានបញ្ចាំងមកហើយ ។ តែ,ដើម្បីវិនិច្ឆ័យថា រឿងណាចំរើនឬអន់ថយត្រង់ណាៗនោះ គប្បីយើងសម្រេចលក្ខណការណ៍ជាមុនសិន ។ រឿងភាពយន្តគឺដូចជាមែកធាងឯទៀតៗនៃវប្បធម៌ និងចំរើនបាន លុះ

ណាតែបានបំពេញលក្ខណៈជាតិ, វិទ្យាសាស្ត្រ និងប្រជាធិបតេយ្យជាអាទិ ក្នុងអត្ថន័យសិន ។

ទី១) គឺមានការៈបញ្ចាំងឲ្យឃើញនូវរូបភាពជាក់ស្ដែងនៃសង្គមជាតិយើង ឬបាតុភូត ឬសភាពដែលអាចនឹងកើតឡើងបាន នៅក្នុងសង្គមជាតិយើង មិនមែនចម្លងពីសៀមបន្តិច ពីកូនបន្តិច ដើម្បីសារុបគ្នាមកធ្វើជាប្រឡាំងកាសទេ ។ លក្ខណៈសៀម ទុកឲ្យសៀមគេលេងទៅ លក្ខណៈកូន កូនគេលេងទៅហើយ ឯលក្ខណៈគោវបោយ ឬស្អីៗប្រហែលៗគ្នានោះ ក៏ជាការៈរបស់គេទេ ។ លក្ខណៈបុរាណរបស់យើង យើងត្រូវតែរក្សាទុកនូវចំណុចល្អ តែនេះទៀតក៏ដើម្បីតែនឹងរកសន្ទុះក្នុងបច្ចុប្បន្នកាល ដើម្បីនឹងឈានទៅអនាគតប៉ុណ្ណោះ មិនមែនគ្រាន់តែរក្សាទេទេ ពីព្រោះសំខាន់ គឺត្រូវទៅមុខ ។ គឺប្រឆាំងលក្ខណៈ អាណានិគមនិយមពុករលួយប្រតិកិរិយា ។ ប៉ុន្តែលក្ខណៈជាតិនេះ ក៏ត្រូវមានទាក់ទងនឹងវប្បធម៌អន្តរជាតិ ចំរើនដែរ មិនមែនងងឹតងងល់តែម្នាក់ឯងនោះទេ ។

ទី២) គឺខំកំចាត់ឲ្យអស់ នៅជំនឿមិនសមហេតុផលគ្រប់បែបយ៉ាង មានអារក្សអ្នកតា ខ្មោចបិសាចជាដើម ។ ឬបើមិនបានដល់ទៅកំចាត់ដោយសកម្មទេ ក៏មិនត្រូវលើកយកជំនឿមកបំផុសដែរ តែត្រូវធ្វើយ៉ាងណា ឲ្យមហាជនបានជ្រួតជ្រាបពីសេចក្ដីចំរើននៃវិទ្យាសាស្ត្រជាស្នាដៃមនុស្ស ឲ្យមហាជនមានទស្សនៈវិទ្យាសាស្ត្របន្តិចម្ដងៗ ។

ទី៣) គឺត្រូវបំរើផលប្រយោជន៍ នឹងសេចក្ដីត្រូវការនៃមហាជន ភាគច្រើន ។ តែខ្សែភាពយន្តក៏មិនត្រូវបញ្ចើចបញ្ចើ ឬធ្វើប្រជាភិថុតិចំពោះមហាជនឡើយ គឺត្រូវដឹកនាំមហាជនទៅរកសេចក្ដីចំរើន សេចក្ដីថ្លៃថ្នូរ នឹងសីលធម៌ ។

ឯចំពោះរូបភាពវិញ នេះអាស្រ័យទៅលើគតិនិករបស់អ្នកដឹកនាំរឿងនឹងអ្នកថតហើយនឹងសមត្ថភាពរបស់ខ្មែរយើង ក្នុងអាជីពថ្មីនេះទេ ប៉ុន្តែបញ្ហានេះមិនជារឿងធ្ងន់ពេកទេ ។

## “ វិសតា ឬ ការកសាង ”

យើងសូមសរសើរដល់ឧត្តមគតិនៃខ្សែភាពយន្តនេះ ដែលមានគំនិតផ្ដើមនឹងយកបញ្ហាបច្ចុប្បន្នភាពមួយ ដ៏មានសារសំខាន់មកចោទ គឺបញ្ហាស្រីពេស្យា ។ អ្នកដឹកនាំរឿងបានមានចេតនាមួយយ៉ាងខ្ពង់ខ្ពស់ក្នុងការធ្វើវិភាគទាន ស្ថាបនាសង្គមកិច្ចរបស់យើង ដោយដាស់តឿននារីផ្នែកនេះឲ្យភ្ញាក់រលឹក ហើយអប់រំគេឲ្យមានចរិយាស្អាតស្អំ កសាងវាសនាខ្លួនជាថ្មីឡើងវិញ ។

ការដែលគួរឲ្យស្ដាយ បើតាមមតិយើង គឺនៅត្រង់ខ្សែភាពយន្តនេះមិនបើកផ្លូវ សុកមង្គលឲ្យនាងដែលបានភ្ញាក់រលឹកហើយនោះ ទៅជាបានទទួលមរណភាពជាលទ្ធផលទៅវិញ ជាហេតុដែលធ្វើឲ្យនារីឯទៀត បាត់ស្មារតីក្នុងការកែខ្លួន ។ មាដែលពង្រាត់បង្រាសក្មួយប្រុសនោះ ត្រូវតែបានទទួលការផ្ដាលផ្ដាញ់និងសេចក្ដីបំភ្លឺពីក្មួយ ។ ហើយទោះបីមានេះយល់ព្រមក្ដី មិនព្រមក្ដី ក្មួយនេះគប្បីប្ដេជ្ញាមករួមរក្សាទឹកកិរិយាខ្លួន ឲ្យតាលតែសំរេចសមដូចនាងស្រីនេះ បានប្ដេជ្ញាកែខ្លួនពីពេស្យាមកធម្មតាដូចនេះ ។

« កូឡាបស្រពោន »

នេះជាហ្វីលដំបូងបង្អស់ ដែលបានយកបញ្ហាយុវជនសិក្សា មកចោទច្រើនជាងគេ ។ ក្នុងរឿងនេះ យើងយល់ស្របនឹងអ្នកនិពន្ធ ត្រង់បានបង្ហាញលក្ខណៈសិក្សាពិត ៗ នៃយុវជននិស្សិតភាគច្រើនរបស់យើង ដែលសិក្សាផង ប្រកបរបរអ្វីមួយផង ដើម្បីយកកំរៃ ។ ហ្វីលនេះក៏បានអប់រំយុវជននិ-ស្សិតយើងឲ្យស្រឡាញ់ការងារពលកម្មទៀតផង ។ នេះជាចំណុចល្អរបស់តួឯក ប៉ុន្តែចំណុចខ្សោយរបស់គេវិញ គឺពាក់កណ្ដាលខាងក្រោយនៃជីវិតរបស់គេ គឺចាប់តាំងពីពេលដែលនិស្សិតប្រុសនេះចាប់ស្រឡាញ់នារីមក ។ ណ្ហើយស្នេហាក៏ស្នេហាទៅចុះ ប៉ុន្តែដល់ទៅស្លាប់ព្រោះតែស្នេហាការនេះ មិនសមនឹងសាច់ដុំរបស់ខ្លួនសោះ ។ យុវជននេះត្រូវតែកាត់ចិត្តឲ្យដាច់ពីនារីដែលខ្លួនយល់ឃើញថា "មិនស្វាមីភក្ដិនឹងខ្លួន" ចេញទៅហើយចាប់បន្តការសិក្សាទៅទៀតវិញ ឬនៅតែដាច់ចិត្តទៀត ក៏ត្រូវខំតស៊ូឲ្យបាន រង់ចាំប្រហែលនាងកញ្ញាជាសង្សារខ្លួននោះទៅ មិនត្រូវដើរផ្សងព្រេងវង្វេងឲ្យឡានបុកទទេ ៗ ដូចនេះឡើយ ។ និយាយពីរូបភាពវិញ យើងយល់ឃើញថា ហ្វីលនេះវែងពេកវែងដោយមិនចេះរកកន្លែងបញ្ចប់ ជាហេតុធ្វើឲ្យគុណភាពរបស់ហ្វីលធ្លាក់ចុះថែមទៀត ។ ហ្វីលនេះ គប្បីបប់តាំងពីពេលឈាបនកិច្ចរបស់សង្សារប្រុសម្ល៉េះ ។

“ផែះគំប្ដី”

មានគោលបំណង នឹងនាំយកឲ្យឃើញនូវគ្រោះថ្នាក់នឹងមហន្តរាយនៃស្វាមីម្នាក់ ដែលភ្លេចករណីយកិច្ចរបស់ខ្លួន ទៅសេពគប់នឹងស្រីសាវ៉ា-សែ ។ ធនធានដែលខ្លួនសន្សំរាប់ឆ្នាំមក ក៏ត្រូវរលត់រលាយទៅវិញយ៉ាងឆាប់រហ័ស កិត្តិយសខ្លួនត្រូវប្រឡាក់ក្រខ្វក់គួរឲ្យខ្ពើម គ្រួសារបិតនៅក្នុងក្ដីគ្មានទីពឹង កូនបានទទួលការអប់រំមួយយ៉ាងសាក្រក់

ដោយឪពុកមិនតាំងដឹងខ្លួនផង ការងាររាជការបំ-រើមហាជន បានត្រូវទេចហើយខ្ជិលៗ ។ល។ នេះជាបញ្ហាបច្ចុប្បន្នភាពមួយនៃប្រទេសយើង ដែលហ្វីលនេះបានផ្ដល់នូវវិភាគទានមួយយ៉ាងធំ។ យើងជឿថាហ្វីលនេះ មិនខាននឹងជះឥទ្ធិពលទៅលើសាម៉ីជនឡើយ ហើយយល់ថា បើគេដោះស្រាយបញ្ហាស្មុគស្មាញនេះបានហើយ នោះគ្រួសារគេប្រជាពលរដ្ឋទូទៅ ព្រមទាំងខ្លួនគេ ក៏បានរស់នៅដោយធូរថយគ្រាន់បើជាង ។

«ស្បៃក្រហម»

ក្នុងចំណោមហ្វីលខ្មែរ យើងស្មានថា នេះជាហ្វីលទី ១ នឹងលេខ ១ ដែលមានសេចក្ដីក្លាហាននឹងបង្ហាញការពិតរបស់ខ្មែរ ។ ក្រោមស្បៃដ៏ខ្មៅងងឹតមួយ ដែលធ្វើឲ្យមតិច្រឡំបល់ ហើយខ្ញាញ់ជាពន់ពេក ។ បញ្ហាដែលគេបានយកមកចោទនោះគ្មាននៅក្នុងប្រទេសយើង ដ៏សីលធម៌ទេ ។ គេនៅតែមិនយល់ថា តើអ្នកនិពន្ធ មើលការពិតខ្មែរដោយភាពច្រឡំ ឬមួយក៏ចង់ធ្វើអាហរណ៍នៃវប្បធម៌សៀមនឹងហ្វីលីពីន មកបញ្ចូលយុវជនខ្មែរយើង ។ តាមពាក្យថាសៀមនឹងហ្វីលីពីននេះ យើងចង់និ-យាយពីពួកពុករលួយ ដែលគេតែងឃើញតាមហ្វីល តែមិនមែនវប្បធម៌របស់ប្រជាជនមហាជនពិតៗ ដែលយើងរមែងគោរពនោះទេ ។ ក្នុងពេលទស្សនាហ្វីលនេះ អ្នកផងនៅតែមាននិន្នា-ការមិនចង់ជឿថាជាហ្វីលខ្មែរ ព្រោះហាក់ដូចជាគេបានគ្រោងទុកជាមុនថា ត្រូវបញ្ចូលការវាយគ្នា "បុកលីប្រ" ប្រាំធាកជាសារវន្ត ហើយយកការវាយនេះមកភ្ជាប់គ្នាឲ្យបានជារឿង ។ ដូច្នេះហើយបានជាខ្សែរឿងគ្មានទាក់ទងខ្សែសង្វាក់គ្នាសោះ ។ សារុបទៅ «ស្បៃក្រហម» បើកឆាកឡើង ដោយការពួយមួយកាំបិតស្នៀត ហើយចប់ទៅវិញដោយសារពួយមួយគ្រាប់ពិស្ដូឡេ ឯខ្លឹមសារបែបប្រតិ-កិរិយាហើយ ប្រសិនជាយើងហ៊ានប្រើពាក្យនេះៗ

មតិ

ចំពោះប្រទេសយើង ភាពយន្តជាអាជីពមួយថ្មី ដែលអ្នកនិពន្ធនឹងអ្នកតិកនិក រមែងតែខ្វះការពិសោធន៍ ដូចនេះហើយ ។ នេះយើងក៏យល់ដែរ ។ ប៉ុន្តែ ទោះជាមានការខុសឆ្គង កាន់ប្រឡំខ្វះក្ដី ដែលជាការធម្មតាទេ យើងចង់ឃើញអ្នកនិពន្ធភាពយន្តយើង ចោទតែបញ្ហាណាដែលជាបញ្ហាខ្មែរយើងដែលមហាជនខ្មែរយើង ត្រូវការឲ្យយើងជួយដោះស្រាយ ដែលយុវជនយើងជាពិសេសកំពុងត្រូវការបំប៉ន ហើយដែលវប្បធម៌នឹងអារ្យធម៌ខ្មែរយើងកំពុងអំពាវនាវឲ្យជួយលំអ ។

ក្នុងន័យនេះ យើងចង់ជួយយោបល់ថា បើមិត្តអ្នកនិពន្ធយើងជួបនឹងការលំបាក ក្នុងការជ្រើសរើសរកនិក្ខេបបទតែង មិត្តអាចនឹងយករឿងដែលមានក្នុងកម្មវិធីសិក្សាមកស្តែងបានដែរ ដែលជាកត្តាមួយជួយដោះស្រាយបញ្ហានិក្ខេបបទរួចស្រេចៗ ធ្វើដូចនេះមិត្តយើង មិនគ្រាន់តែជួយអារ្យធម៌ខ្មែរទេ គេថែមទាំងបានជួយសាស្ត្រាចារ្យ នឹងយុវជនយើងដោយផ្ទាល់តែម្តង ។ ឯការសំរេចជោគជ័យវិញ យើងឃើញថាថែបច្បាស់ណាស់ ពីព្រោះទាំងគ្រូ ទាំងសិស្ស ទាំងមាតាបិតា សុទ្ធតែត្រូវការចង់បានឃើញរឿងដែលខ្លួនបានអាន បានសិក្សា ឬបានឮមកហើយ ដូចជាសូផាត ផ្កាស្រពោន ..ហើយបើកូឡាបប៉ៃលិន ឬទុំទាវដែលជារឿងក្នុងកម្មវិធីថ្នាក់ទី៣វិញនោះ មិនបាច់និយាយពីជោគជ័យទេ ។

យើងសូមសរសើរ ដល់មិត្តអ្នកនិពន្ធខ្មែរទាំងអស់ ដែលបានខំធ្វើវិភាគទានដល់វប្បធម៌ជាតិតាមសមត្ថភាពខ្លួន ទោះតិចក្តីច្រើនក្តី ហើយសង្ឃឹមថាហ្វីលក្រោយៗ កាន់តែមានគុណភាពជាងមុនៗ ហើយសូមប្រសិទ្ធិពរ ឲ្យបានសំរេចជោគជ័យដ៏ចែងចាំងរឿងៗខ្លួន ។

# ជាតិជាខ្មែរ

ភ្លេង និង ទំនុក
ក. សុវន



១- ខ្មែរយើងកូនខ្មែរ ទោះនៅក្រុង ទោះនៅស្រែ យើងសុទ្ធតែកូនចៅខ្មែរ ខ្មែរកុលបុត្រខ្មែរ ស្រឡាញ់ភូមិ ស្រឡាញ់ស្រែ ស្រឡាញ់តែទឹកដីខ្មែរ យើងជាយុវជន ប្រកាន់វិន័យមាំមួន ពោលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រយោជន៍ជាតិយើង ការពារវឌ្ឍនភាព បូរណភាពខ្មែរទឹងហ្ន៎ ការពារជាតិវប្បធម៌គង់វង្ស ល្អកេរ្តិ៍ឈ្មោះខ្ពង់ ខ្មែរយើងជឿខ្មែរ គឺមានតែឈាមខ្មែរ ទើបស្រឡាញ់ខ្មែរដូចខ្មែរ ។

២- ខ្មែរ ជាតិជាខ្មែរ កូនអ្នកក្រុង កូនអ្នកស្រែ យើងរួមខ្សែជាធ្លុងមួយ ខ្មែរ សាមគ្គីខ្មែរ ទើមបម្យាំងរួមប្រឆាំង នឹងអំពើពុករលួយ ចិត្តត្រង់នឹងវង្ស ប្រាកដវិន័យយុវជន ទើមអំពើជិះជាន់ នឹងអំពើក្បត់លក់ខ្លួន គ្មានពួកបក្សពត្តិណា ស្រឡាញ់ខ្មែរជា. ជាងខ្មែរ ឬ ការប្រយោជន៍ខ្មែរ ជាជាងខ្មែរ ដែលរួមឈាមគ្នា ខ្មែរ យើងជឿខ្មែរ គឺមានតែឈាមជាខ្មែរ ទើបស្រឡាញ់ខ្មែរ ដូចខ្មែរ ។

សូមមិត្តទាំងឡាយ

សុំចុះឈ្មោះចូលជាសមាជិក

សមាគមសាស្រ្តាចារ្យខ្មែរ(ស.ស.ខ)




# ញត្តិរបស់សមាគមសាស្ត្រាចារ្យខ្មែរ

## សូមព្រះតេជៈដំកល់លើត្បូង

## សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ សម្តេចព្រះប្រមុខរដ្ឋ

## សូមទ្រង់ជ្រាបក្រោមលម្អងធូលីព្រះបាទ

ដោយយល់ឃើញថាសភាពការណ៍ប្រទេសជាតិ មានអាសន្នមកពីការគំរាមកំហែងពីប្រទេសសៀម និងវៀតណាមខាងត្បូង ដែលជាសមាជិកនៃសេអាតូ ក្រោមកិច្ចបញ្ជាចក្រពត្រអាមេរិក

ដោយឈឺចាប់នឹងអំពើប្រមាថរបស់សារគេថាណាភត និងរបស់បណ្ណកាសែតនៅបស្ចិមប្រទេស ចំពោះអង្គសម្តេចនិងចំពោះប្រជាជាតិខ្មែរ

ទូលព្រះបង្គំយើងខ្ញុំ ជាសមាជិកនៃសមាគមសាស្ត្រាចារ្យខ្មែរ សូមឧបត្ថម្ភសម្តេចព្រះប្រមុខរដ្ឋ អស់ពីកំឡាំងកាយនិងកំឡាំងចិត្ត ក្នុងគ្រាអាសន្នដល់អាយុជីវិតជាតិយើងនេះ ។

សមាគមយល់ថាអធិករណ៍នេះ មិនមែនជាទំនាស់រវាងអង្គសម្តេចនិងរដ្ឋការអាមេរិកតែប៉ុណ្ណោះទេ គឺពិតជាបាតុភាព នៃការរំលោភរបស់ចក្រពត្តិមកលើឯករាជ្យនិងអព្យាក្រឹត្យប្រជាជាតិខ្មែរ ។ ព្រះកាយវិការនិងព្រះរាជឧក្ការទាំងអម្បាលមាណសុទ្ធតែសំដែងត្រូវតាមចិត្តថ្លើមនិងស្របតាមផលប្រយោជន៍ជាតិទាំងមូល ។

អាស្រ័យហេតុនេះទូលព្រះបង្គំយើងខ្ញុំ សូមអង្វរសម្តេចសូមព្រះអង្គទ្រង់គង់នៅជាប្រមុខរដ្ឋ ដឹកនាំប្រទេសជាតិតទៅទៀត ។ ទូលព្រះបង្គំទាំងឡាយ សូមប្តេជ្ញារក្សាសាមគ្គីភាពយ៉ាងជិតស្និទ្ធជុំវិញព្រះអង្គ ក្នុងព្រះរាជបេសកកម្មការពារឯករាជ្យអព្យាក្រឹត្យជូនមាតុប្រទេស ។

សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃ ៤វិច្ឆិកា១៩៦១

សមាជិកសមាគមសាស្ត្រាចារ្យ

បានចុះហត្ថលេខា:សមាជិកនៅភ្នំពេញចំនួន ១៣៥ នាក់ ។

# សេចក្ដីថ្លែងអំណរគុណពីមិត្តម្នាក់ ចេញពីពេទ្យ

ខ្ញុំមានបីតិសោមនស្សជាពន្លឹក នឹងសូមថ្លែងនូវអំណរគុណដ៏ស្មោះស្ម័គ្រដល់សមាគមសាស្ត្រាចារ្យខ្មែរ ចំពោះការឈឺឆ្អាលយកចិត្តទុកដាក់សាកសួរជម្ងឺរបស់ខ្ញុំ ។ កាលពីខែមិថុនា ឆ្នាំ ១៩៦១ ក្នុងនាមនៃសមាគម លោក កែ សុខន នឹង លោក កង់ គិតហុយ ជាសមាជិកនៃគណៈកម្មាធិការនាយក បានទៅសាកសួរជម្ងឺខ្ញុំឯមន្ទីរពេទ្យ «បេស៊ីយែរ» ដោយមេត្រីចិត្តស្និទ្ធស្នាលបំផុត ។

ភស្តុតាងនេះបង្ហាញយ៉ាងច្បាស់នូវទឹកចិត្តយ៉ាងថ្លៃថ្លាប្រកបដោយឧត្តមគតិពិសេសរបស់សមាគមសាស្ត្រាចារ្យខ្មែរយើង ។

ដូចនេះ សូមមិត្ត-សមាជិកទាំងឡាយនៃសមាគមសាស្ត្រាចារ្យ មេត្តាទទួលអំពីខ្ញុំនូវសេចក្ដីរាប់អានយ៉ាងឧត្តុង្គឧត្តម ។

ព្រហ្ម-ឈួន ជុល

ក្រោយដែលបានដំណឹងថាផ្លាស់លោក ទីវ-អុល ពីសាលាជាតិខាងសិល្បៈនិងមុខរបរ សមាគមបានចាត់ប្រធាន អនុប្រធាននិងអគ្គលេខាធិការ ឲ្យនាំសំបុត្រខាងក្រោមនេះ ទៅជូន ឯ.ឧ. រដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងវិចិត្រសិល្បៈ ៖

គណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

ជូនដល់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំជាតិនិង

វិចិត្រសិល្បៈ នៅភ្នំពេញ

ឯកឧត្តម

ដោយបានទទួលសេចក្តីចំឡងលិខិតខចច្បាប់ ដែលលោកសាស្ត្រាចារ្យ ទីវ-អុល បានផ្ញើជូនឯកឧត្តម ចុះថ្ងៃ ១៩ កញ្ញា ១៩៦១ គណៈកម្មាធិការនាយកសមាគមបានប្រជុំគ្នា ពិនិត្យរឿងហេតុ ដែលនាំឲ្យសាស្ត្រាចារ្យនេះ ត្រូវផ្លាស់ចេញពីសាលាជាតិខាងសិល្បៈនិងមុខរបរ ។

លោក ទីវ-អុល បានត្រូវផ្លាស់ចេញនៅកណ្តាលឆ្នាំសិក្សា ហើយនៅក្នុងសម័យដែលលោកកំពុងតែបំពេញ stage ផង ។ ដូច្នេះសាស្ត្រាចារ្យនេះមិនដឹងជាបញ្ចប់ stage ខ្លួនយ៉ាងណាទេ នៅក្នុងឱកាសមួយដែលសាលានានា កំពង់តែខ្វះសាស្ត្រាចារ្យខ្មែរបង្រៀន ។ យើងខ្ញុំមិនទាន់ដឹងច្បាស់ថាសាស្ត្រាចារ្យនេះបានប្រព្រឹត្តកំហុសអ្វីនៅឡើយទេ ប៉ុន្តែការផ្លាស់ដោយបន្ទាន់នេះមានលំនាំដូចជាផ្តន្ទាទោស ( sanction ) ជាហេតុឲ្យសាមីខ្លួនខូចផលប្រយោជន៍ និងក្រឡុកទឹកចិត្តក្នុងកិច្ចបំពេញការងារខ្លួន ។ ទោះជាយ៉ាងណា បើមានការឆ្គាំឆ្គងម្តេចម្តា គួរតែនាយកសាលាហៅសាមីខ្លួនមកដំរេដំរង់ ឬព្រមានមួយដង ឬពីរដងសិនដែរ ។

អាស្រ័យហេតុនេះ គណៈកម្មាធិការនាយកសមាគម ដែលទទួលភារៈគិតគូរដល់ផលប្រយោជន៍សាស្ត្រាចារ្យជាសមាជិក សូមផ្ញើសេចក្តីទុកចិត្តលើឯកឧត្តម សូមឯកឧត្តមពិនិត្យរឿងនេះដោយសុភនិច្ឆ័យ និងដោយអនុគ្រោះឲ្យមានដើម្បីឲ្យសាមីខ្លួន បានធ្វើការនៅកន្លែងដែលដូចពាក្យសុំ និងដើម្បីឲ្យយើងខ្ញុំឯទៀតជាសាស្ត្រាចារ្យបានកក់ក្តៅតទៅអនាគត ។

សូមឯកឧត្តមទទួលសេចក្តីគោរពអំពីយើងខ្ញុំ

ធ្វើនៅភ្នំពេញនៅថ្ងៃ ២៧ កញ្ញា ១៩៦១

គណៈកម្មាធិការនាយក

(ក្រៅពីហត្ថលេខាគណៈកម្មាធិការនាយកមានសមាជិកនៅភ្នំពេញចំនួន ២១៨ នាក់ទៀតបានចុះហត្ថលេខាថ្លែងសេចក្តីយល់ស្របនិងឧបត្ថម្ភសំបុត្រនេះ)

ក្នុងពេលក្រោយបង្អស់នេះ សមាគមយើងបានទទួលសំបុត្រពីអនុវិទ្យាល័យស្លួង ដែលមានសាស្ត្រាចារ្យ២៥ នាក់ និងពីវិទ្យាល័យព្រះសីហនុ មានសាស្ត្រាចារ្យចំនួន ១៤ នាក់បានផ្ញើសំបុត្រមកសុំឲ្យប្រធានសមាគមការពារសិទ្ធិ សេរីភាពសាស្ត្រាចារ្យឲ្យបានម៉ឺងម៉ាត់ ក្នុងការផ្លាស់ប្តូរមិនសមហេតុសមផល ដូចជាការផ្លាស់ប្តូរលោកទីវ-អុលជាដើម ។

# វិទ្យា & សិល្បៈ

## តើយើងគប្បីហាត់ប្រាណឬទេ ?

ទស្សនវិទូជាច្រើនបានថ្លែងគំនិតគ្នា ខ្លះនិយមយកចិត្តជាធំ ខ្លះទៀតយករូបកាយវិញ ។ តាមការពិត មនុស្សយើងគឺជាសំយោគផ្សំរវាងចិត្តនឹងកាយជាដាច់ខាត ។ លុះរូបកាយកើតមានរួចមកហើយ ទើបជីវិតិន្ទ្រីយមានតាមក្រោយ ។ ហេតុនេះហើយបានជាមានមតិនិយមថារូបកាយជាគ្រឿងសំរាប់ទ្រទ្រង់នូវជីវិតិន្ទ្រីយ ។ គឺជាការនិយមភ្ជាប់រវាងចិត្តនឹងកាយនេះហើយ ដែលមិនអាចធ្វើឲ្យយើងបំភ្លេចកាយវប្បកម្មបាន ពោលគឺការហាត់ប្រាណនេះឯង ។

ការពិសោធន៍ធ្លាប់បានប្រាប់យើងរួចមកហើយថា ពេលណារូបកាយយើងមានវិបត្តិ ពេលនោះជីវិតិន្ទ្រីយយើងក៏ត្រូវទទួលវិបាកជាស្វ័យប្រវត្តិ ។ អាស្រ័យហេតុនេះ ដើម្បីរក្សានូវសមស្សរៈ ក្នុងមនុស្សម្នាក់ៗ គប្បីយើងប្រព្រឹត្តកាយវប្បកម្មឲ្យបានញឹកញយផង ព្រោះអាត្មនបរិសុទ្ធ អាចរស់បានតែក្នុងរូបកាយមានសុខភាពប្រសើរប៉ុណ្ណោះ ។ តើការហាត់ប្រាណមានអានុភាពអ្វីខ្លះទៅលើរូបកាយរបស់មនុស្ស ?

អ្នកកីឡាកំពុងរត់ ត្រូវដកដង្ហើម ៧ ដងច្រើនជាងមនុស្សដេកនៅស្ងៀម ។ ការទំលាប់ស្រូបយកខ្យល់ច្រើនយ៉ាងនេះ ជាមធ្យោបាយមួយយ៉ាងស័ក្តិសិទ្ធិ សំរាប់បង្កើតបង្កើនដល់សួតឲ្យមានទំហំរីកធំ ។ ជាពិសេសក្នុងពេលហាត់ប្រាណម្តងៗ សាច់ដុំតាំងប៉ុន្មាន ដែលពាក់ព័ន្ធក្នុងយន្តសាស្ត្រនៃការដកដង្ហើម ត្រូវបានហ្វឹកហ្វឺនសំរាប់បង្កើនកម្លាំងជានិច្ច ដែលជាហេតុបណ្តាលឲ្យដើមទ្រូងរីកបានជាអតិបរមា ។ រួចគឺហេតុតែនេះហើយ ដែលអនុញ្ញាតឲ្យអុកស៊ីហ្សែនចូលទៅលាងឈាមបានបរិសុទ្ធល្អ ។ ឯសរីរាង្គកាយ កាលបើបានឈាមស្អាតបាតមកចិញ្ចឹមជីវិតហើយ នោះក៏ប្រកបទៅដោយសុខភាពតាមនោះដែរ ។

មិនតែប៉ុណ្ណោះសោត ការហាត់ប្រាណមានសមត្ថភាព អាចសម្រួលដំណើរឈាមរត់ថែមទៀតផង ។ យ៉ាងណាមិញ ការកំរើកសាច់ដុំញឹកញាប់តែងតែបណ្តាលឲ្យមានកំដៅក្នុងសរីរាង្គកាយជានិច្ច ។ កំដៅនេះអាចដុតសរសៃឲ្យរីកធំបាន ដែលជាហេតុនាំឲ្យឈាមអាចរត់បានរហ័សហើយច្រើនផង ។

ម្យ៉ាងទៀត សាច់ដុំដែលបញ្ចេញថាមពល ត្រូវបរិភោគឈាមច្រើនណាស់ ។ ម្ល៉ោះហើយឈាមក៏ត្រូវបង្ខំរត់ឲ្យច្រើន ដើម្បីតម្រូវការខ្វះខាតនេះ ។ ឯសរសៃ កាលបើឈាមប្រជ្រៀតគ្នារត់យ៉ាងនេះ ហើយក៏តោងពង្រីកផ្លូវរបស់ខ្លួនផងដែរ ។ ហេតុទាំងពីរខាងលើនេះ ទៅបង្ខំបេះដូងឲ្យធ្វើសកម្មភាពយ៉ាងខ្លាំងក្លា ។ បេះដូង កាលបើធ្លាប់ទទួលការហាត់ប្រាណយ៉ាងនេះ ក៏បានរីកធំហំផង បានបង្កើនកម្លាំងផង ។ គឺដោយសារតែកម្លាំងនៃបេះដូងនេះហើយដែលឈាមយើងអាចរត់ទៅចិញ្ចឹមសាច់សព្វសព៌ាង្គកាយបាន ។ សំខាន់បំផុត ការប្តូរឈាមនៅផ្នែកខួរក្បាលក៏អាចប្រព្រឹត្តទៅយ៉ាងស្រួល ដែលជាហេតុអាចឲ្យយើងសំរេចកិច្ចការខាងបញ្ញាបាន ។ បើប្រព័ន្ធសរសៃ មានដំណើរជាសុក្រឹតហើយ សុខភាពរូបកាយក៏នឹងកើតមានជាពិតប្រាកដ ។

ការហាត់ប្រាណ មិនត្រឹមតែធ្វើឲ្យយើងអាចដកដង្ហើមគ្រប់គ្រាន់ និងសម្រួលដំណើរឈាមរត់ប៉ុណ្ណោះទេ ក៏ប៉ុន្តែអាចជួយកិច្ចការរំលាយអាហារថែមទៀតផង ។ វិប្បកម្មខាងសាច់ដុំ ពោះ ជាកត្តាមួយយ៉ាងឆ្នើម សំរាប់ដម្លើងកម្លាំងគ្រឿងប្រដាប់រំលាយអាហារផ្សេង ដូចជាក្រពះនិងពោះវៀនជាដើម ។

ក្រៅពីនេះ ការហាត់ប្រាណមានសមត្ថកិច្ចច្រើនទៀតដូចជា: ការបញ្ចេញលាមកតាមញើស ការបង្គាប់បញ្ជារបស់ខួរក្បាលទៅលើសាច់ដុំ (ឲ្យមានលក្ខណៈរហ័សរហួននិងច្បាស់លាស់), ការបរិភោគអាហារបានច្រើន (ដោយសាច់ដុំត្រូវការអាហារច្រើននៅពេលបញ្ចេញថាមពល) ។ល។

សារុបសេចក្តីទៅឃើញថាការហាត់ប្រាណអាចផ្តល់នូវសុខភាព ដល់អ្នកធ្វើកាយវិប្បកម្មបានជាដាច់ខាត ។ ក៏ប៉ុន្តែការហាត់ប្រាណ នៅមានសមត្ថភាពសំខាន់មួយទៀត គឺឆ្លាក់រូបរាងកាយរបស់មនុស្សឲ្យមានសមស្រប: សមតាមសោភណភាពដែលសង្គមមនុស្សត្រូវការ ។

គេហដ្ឋានយ៉ាងប្រណីតនិងជាសុក ធ្វើឲ្យមនុស្សសប្បាយរីករាយយ៉ាងណា ជីវិតទ្រើយដែលរស់នៅក្នុងរូបកាយប្រកបដោយសុខភាព ក៏យ៉ាងនោះដែរ ។



# ដំណើរទស្សនកិច្ច

## នៃគណៈប្រតិភូ សាស្ត្រាចារ្យខ្មែរ
## នៅប្រទេសចិនប្រជាមានិត

### មិត្តអ្នកអាន

ដោយសេចក្តីស្នើសុំ អំពីគណៈកម្មការកណ្តាល នៃសមាគមសាស្ត្រាចារ្យ ឲ្យខ្ញុំពណ៌នាអំពីទស្សនកិច្ច នៅប្រទេសមហាមិត្តចិនប្រជាមានិត ខ្ញុំក៏មានចិត្តរីករាយនឹងជូនជាដំណឹងដល់មិត្តអ្នកអាន នូវពត៌មានខ្លះ ដែលខ្ញុំបានឃើញ បានឮ និងបានយល់ៗ ដូចមិត្តខ្លះបានជ្រាបហើយថា ដោយសេចក្តីអញ្ជើញនៃរដ្ឋាភិបាលចិន រាជរដ្ឋាភិបាលយើងក៏បានចាត់គណៈប្រតិភូសាស្ត្រាចារ្យមួយមានសមាជិក ៣ រូប ឲ្យទៅធ្វើទស្សនកិច្ចនេះ ដើម្បីរឹតចំណងមិត្តភាពរវាងប្រទេសយើងទាំងពីរ ។ គណៈប្រតិភូមានសមាសភាពដូចតទៅនេះ :-

– លោក គិម-យិនស៊ុំសាមុត, ចាងហ្វាងទូទៅនៃសាលាឯកជន ជាប្រធាន,

– អ្នកគ្រូ ពៅ-សាយុន សាស្ត្រាចារ្យ និង

– លោក ឈ័រ-គិម-ហុង នាយកវិទ្យាល័យ ជាសមាជិក ។

ខ្ញុំត្រេកអរច្រើន កាលបើបានទទួលដំណឹងថា រាជរដ្ឋាភិបាលបានតម្រូវខ្ញុំជាសមាជិកនៃគណៈប្រតិភូនេះ ព្រោះតាំងពីនៅវ័យក្មេងខ្ញុំមកតែងចាប់អារម្មណ៍ចំពោះប្រទេសចិនជាច្រើន ដោយៈ

១– កាលណាក្រឡេកលើផ្ទាំងផែនទីសកលលោកនោះ ចក្ខុរម្មណ៍តែងផ្ចិតទៅលើទំហំដីធំធេងនៃប្រទេសចិន ។ ម្ល៉ោះហើយបំណងដែលចង់ឃើញពិតប្រាកដនូវន័យ នៃពណ៌និងសញ្ញាទាំងឡាយផ្សេងៗ ដែលគេគូរពាសលើផ្ទាំងផែនទី ក៏កើតមានជាលំដាប់ៗ

២– រឿងព្រេង រឿងប្រលោមលោក ពង្សាវតារ ឬសេចក្តីអធិប្បាយទាំងឡាយផ្សេងៗ ស្តីអំពីប្រទេសចិនតែងទាក់អារម្មណ៍ខ្ញុំជាច្រើន ។ តាំងពីក្មេងម្ល៉េះខ្ញុំស្គាល់ឈ្មោះ ជីវតាគិន និងឮសូរឈ្មោះសាមកុកៗ ម្យ៉ាងទៀត ការប្រែប្រួលយ៉ាងខ្លាំងនៃប្រទេសចិនក្នុងបច្ចុប្បន្នកាលនេះ ដោយខ្ញុំអាចដឹងឮតាមវិទ្យុទស្សនាវដ្តី ឬសារពត៌មាន រឹតតែជម្រុញចិត្តខ្ញុំឲ្យមានបំណងចង់ស្គាល់ជាក់ច្បាស់ថែមទៀត ។

៣-ការរស់នៅរៀនរាល់ថ្ងៃជាមួយជនជាតិចិនក៏ជាបុព្វហេតុមួយដែលនាំឲ្យខ្ញុំ ចង់ដឹងចង់ស្គាល់នូវឫសគល់នឹងដើមកំណើតនៃជនជាតិនេះណាស់ដែរ

ខ្ញុំយល់ថា មិត្តទាំងឡាយក៏ចង់ទស្សនាប្រទេសចិនគ្រប់ៗគ្នា អាស្រ័យហេតុនេះ ខ្ញុំសោមនស្ស នឹងអញ្ជើញមិត្តធ្វើដំណើរជាមួយនឹងគណៈប្រតិភូសាស្ត្រាចារ្យយើង ..អញ្ជើញ !



គណៈប្រតិភូចាប់ចេញដំណើរ តាមអាកាសចរកូម៉ិនកម្ពុជា នៅថ្ងៃ២៣តុលា វេលាម៉ោង៩ព្រឹក ។ ពីកំពស់៥០០០ម ផ្ទាំងពសុធាមានសភាពដូចជាផែនផាសដោយស្មៅពណ៌ខៀវ គ្រង់កន្លែងព្រៃ នឹងដោយស្មៅពណ៌បៃតង គ្រង់វាលស្មៅ ឬវាលស្រែ ។ រយៈដំណើរអស់ពេល៤ម៉ោង ទើបដល់ក្រុងហុង- កុង។ តាមបុករួមទៅ ត្រូវដល់ម៉ោង ១៣; តែដោយម៉ោងនាទីនេះ លឿនជាងយើង២ម៉ោង ក៏ទៅដល់ម៉ោង១៥វិញ ។ នៅចំណតអាកាសយានមានភ្នាក់ងារទេសចរ ចិនមកទទួលនឹងនាំគណៈប្រតិភូទៅដាក់សណ្ឋាគារ"ហ្គូលដេនហ្គេត" ។

## ក្រុងហុង-កុង

"ហ្គូលដេនហ្គេត" ជាសណ្ឋាគារមួយដ៏ស្កុកស្កម្ភ ដោយច្រើនតែជនជាតិអាមេរិកាំងនឹង អឺរុប ឈប់សំណាក់ៗ ក្នុងបន្ទប់នីមួយៗគេឃើញមានវិទ្យុ អាងងូតទឹក អាងម៉ាស៊ីនទឹកត្រជាក់-ក្ដៅ បង្គន់ នឹងម៉ាស៊ីនអាកាសត្រជាក់ ។ការឡើងចុះទៅជាន់នីមួយៗ សុទ្ធតែធ្វើដោយទ្រុងអគ្គិសនី ។ នៅក្រុងហុង កុង គណៈប្រតិភូដើរទៅណាមកណាដោយសេរីខ្លួនឯង ព្រោះរដ្ឋាភិបាលចិនឥតមានចាត់តំណាងមកជាអ្នកណែនាំដើម្បីទស្សនាក្រុងនេះឡើយ ។ នៅថ្ងៃ២៥តុលា វេលាម៉ោង ៩,១៥ គណៈប្រតិភូក៏បានជិះរថភ្លើងសំដៅចូលប្រទេសចិន ។ រយៈដំណើរអស់ពេលមួយម៉ោង ក៏បានទៅដល់ប្រទល់ដែន ។អ្នកដំណើរទាំងឡាយបានចាកចេញពីរថភ្លើងនេះ ដើម្បីដើរដំរង់ទៅចំណតអយស្ម័យយាន ចិនប្រជាមានិត ដែលនៅចម្ងាយពីនេះប្រហែល ៤០០ម ។



តាមផ្លូវចូលទៅ គេឃើញមានរូបផ្សេងៗ ច្រើនៈ រូបប្រធាន ម៉ៅ ត្សេ-ទុង រូបកម្លាំងរួម រូបចំរើនឧស្សាហកម្ម ។ល។

មានអ្នកតំណាងរដ្ឋាភិបាលចិន៣រូប មករង់ចាំទទួលគណៈប្រតិភូយើងគឺ៖

១- លោកស្រីខាងក្រសួងសិក្សាមួយរូប ដែលនឹងនៅជាប់ជាមួយគណៈ ប្រតិភូ ជាអាចិន្ត្រៃក្នុងដំណើរទស្សនកិច្ច ។

២-អ្នកប្រែភាសាជាប្រចាំមួយរូប ដោយមិនទាន់មានអ្នកប្រែភាសាជាខ្មែរ។ រដ្ឋាភិបាលចិនបានតាំងអ្នកបកប្រែនេះ ជាបណ្ដោះអាសន្ន ។ លុះបន្តដំណើរពីក្រុងប៉េកាំងទៅទៀត ទើបមានជាប់ជាមួយនូវនាងមួយរូបសំរាប់បកប្រែជាខ្មែរ ។

៣-អ្នកដំណាងសិក្សាធិការខេត្ត ក្វាំង-តុង មួយរូប ។

ក្រោយដែលបរិភោគបាយថ្ងៃរួចហើយគណៈប្រតិភូ ក៏បន្តដំណើរតាមរថភ្លើងទៅកាន់ក្រុង ក្វាំង-ចូវ ដែលក្នុងផែនទីមានឈ្មោះថា ក្វាំង-តុង ។ តាមពិត ក្វាំង-តុង គឺជាឈ្មោះខេត្ត ឯក្រុងជាទីមានឈ្មោះជាក្វាំង ចូវ;រយៈដំណើរអស់រវាង២ម៉ោង ។

## ក្រុង ក្វាំង ចូវ

គណៈប្រតិភូឈប់សំណាក់នៅសណ្ឋាគារមួយដ៏សុកសុម្ម ដែលសង់ឡើងនៅមាត់ទន្លេ ស៊ុ-ក្យាង ។ សូមជំរាបមិត្តថា ក្នុងរយៈទស្សនកិច្ច គណៈប្រតិភូសុទ្ធតែឈប់សំណាក់និងបរិភោគនៅសណ្ឋា-គារ ជាដរាប ទីណាតែងជួបប្រទះនូវគណៈប្រតិភូប្រទេសទាំងឡាយដ៏ទៃទៀតជាច្រើន ។ ម្យ៉ាងទៀត នៅក្រុងនីមួយៗរដ្ឋាភិបាលចិនតែងប្រចាំរថយន្តបពីរ សំរាប់ជូនដំណើរទស្សនកិច្ចនៃគណៈប្រតិភូយើង ។ នៅពេលចុះឡើង នាចំណតរថភ្លើងនីមួយៗតែងមានដំណាងសិក្សាធិការមករង់ចាំទទួល និងជូនដំណើរយ៉ាងរាក់ទាក់និងដោយស្មាមីភក្ដិ ។ ជួនកាល មានយុវជនចាំជូនបាច់ផ្កាជាទឡ្ហីករផង។ នារសៀលថ្ងៃទៅដល់ក្រុង ក្វាំង-ចូវ គណៈប្រតិភូបានទៅទស្សនា អាគារសំរាប់តាំងវត្ថុផ្សេងៗ ដែលនឹងលក់ទៅបរទេស។ នៅក្នុងនោះ គេមានដាក់តុតូច ៗ សំរាប់ឈ្មួញអង្គុយ គេពិភាក្សារវាងគ្នា ។ នៅក្នុងអាគារនេះ ត្រង់បន្ទោះចូល គេមានតាំងរូបលោកប្រធានម៉ៅ សេ-តុង មួយដ៏ធំសម្បើមដែលមានកំពស់ប្រហែល ៤ម ។ សូមមិត្តជ្រាបថា នៅអាគារសាធារណៈឯទៀតៗ ក៏ច្រើនមានរូបលោកប្រធានរបៀបនេះដែរ ។

នៅរាត្រី លោកចាន់ហ្វាន់ទូតៅវាន់សិក្សាធិការនៃខេត្ត ក្វាង-ទុង បានរៀបពិធីជប់លៀងដើម្បីជាកិត្តិយសដល់គណៈប្រតិភូសាស្ត្រាចារ្យ ។ ពិធីជប់លៀងបែបនេះ តែងមានធ្វើជានិច្ច នៅឱកាសដែលគណៈប្រតិភូ ហៀបចាកចេញពីទីក្រុងនីមួយ ៗ ក្នុងពិធីនោះ គេបានលើកកែវដើម្បីមិត្តភាពជានិរន្តរ៍រវាងចិន-ខ្មែរ ដើម្បីសេចក្ដីចំរើននៃការផ្លះប្ដូរវប្បធម៌ចិន-ខ្មែរ ដើម្បីសេចក្ដីចំរើននៃសិក្សាធិការជាតិយើងទាំងពីរ ។ល។ របៀបធ្វើនីមុខម្ហូប ច្រើនប្លែកពីក្រុងមួយ ទៅក្រុងមួយ និងពីខេត្តមួយ ទៅខេត្តមួយ ។

នៅព្រឹកថ្ងៃ ២៦ តុលា ម៉ោងប្រាំបី គណៈប្រតិភូក៏បានចាកចេញក្រុង ក្វាង-ចូវ ដើម្បីជិះរថភ្លើងឆ្ពោះទៅក្រុង "វូ-ហាន់" ដែលមានចម្ងាយចំនួន ១១០០គ.ម តាមដំណើរជាមួយ ។ ក្រៅពីគណៈប្រតិភូបីនាក់មានលោកស្រីមួយរូបជាអ្នកជូននិងអ្នកបកប្រែភាសាមួយទៀត ។ នៅបន្ទប់រថភ្លើងនីមួយមានគ្រែដេក ៤ គឺគ្រែសងខាង២ និងគ្រែពីលើ ២ ទៀត ចំពោះអ្នកដំណើរផ្លូវជិត គេមានបន្ទប់សំរាប់ដោយឡែក នៅបន្ទប់នីមួយៗ តែងមានឧគ្ឃោសនស័ព្ទ ។ មុនដល់ចំណតនីមួយៗ គេតែងផ្សាយជាដំបូន្មាន ដើម្បីជៀសវាងគ្រោះថ្នាក់ ។ ប្រទេសចិនច្រើនមានសភាពជាភ្នំ តែបន្ទោះណាអាចធ្វើផលិតផលបាន គេឥតមានទុកឲ្យសល់ទំនេរឡើយ ។ ម្យ៉ាងទៀត គេខិតខំដាំដើមឈើយ៉ាងក្រៃលែង នៅច្រើនកន្លែង កម្មករស្ម័គ្រចិត្តបានជីករណ្ដៅសំរាប់ដាំកូនឈើ ។ ការធ្វើទាំងនេះសុទ្ធតែប្រណាំងប្រជែងគ្នា ដើម្បីដណ្ដើមយកលទ្ធផលឲ្យបានច្រើនគ្រប់ៗគ្នា ។ តាមរថភ្លើងខ្ញុំតែងប្រទះឃើញពាក្យ ស្លោកជាច្រើនដែលគេបានសរសេរនៅតាមចង្កេះភ្នំតាមដំបូលឬជញ្ជាំងផ្ទះ តាមភ្លឺស្រែ ដូចជាជ័យោប្រជាសហគម ជ័យោមាគ៌ាទូទៅ ជ័យោមហាលោតផ្លោះ ។ល។ កាលណារថភ្លើងបើកមកដល់ ទេសភាពគួរជាទីចាប់អារម្មណ៍ ដូចជាត្រង់ចង្កេះភ្នំ ដែលមានជ្រោះជ្រៅលន្លោច គេក៏មានចាក់បទភ្លេងឲ្យស្រមនឹងបរិយាកាសនេះ ។ គណៈប្រតិភូបានទទួលទានដំណេកលើរថភ្លើងនេះមួយយប់ដល់ព្រឹកឡើងថ្ងៃ ២៧ តុលា រវាងម៉ោង៨ទើបបានដល់ចំណតក្រុង "វូ-ហាន់" ។

ក្រុង "វូ-ហាន់" តាមផែនទីច្រើនមានឈ្មោះជា ហាន់-គីវ ។



កាលណាដល់ទីក្រុងនីមួយៗ ចាងហ្វាងទូទៅខាងសិក្សាធិការនៃខេត្តនោះ តែងមកពិភាក្សាជាមួយគណៈប្រតិភូនូវកម្មវិធីនៃទស្សនកិច្ច ម្យ៉ាងទៀត ក្រៅពីអ្នកធ្វើដំណើរជាប់ជាមួយ ២ នាក់ តែងមានមួយនាក់ ឬពីរនាក់ សំរាប់ណែនាំទៀត ក្នុងកិច្ចទស្សនាក្រុងនីមួយៗ នៅជាទី "វ៉ូ-ហាន់"ៗ គណៈប្រតិភូបានទស្សនា ៖-

១_សួនកុមារ សំរាប់ក្មេងពីអាយុ ៣ ទៅ ៦ឆ្នាំ· នៅគ្រប់គ្រឹស្ថានដែលគណៈប្រតិភូបានទៅធ្វើទស្សកិច្ចនោះ សាលារៀនឬរោងចក្រក្តី គេតែងមានបន្ទប់សំរាប់ទទួលភ្ញៀវៗ ដល់ភ្លាមគេចាប់បំរើទឹកតែ រួចទើបចាងហ្វាងនៃគ្រឹះស្ថាននោះ អធិប្បាយអំពីស្ថានភាពនៃសាលារៀន ឬរោងចក្រដែលខ្លួនកាន់កាប់ ។ ក្នុងសួនកុមារនេះ គេបានចាត់ក្មេងឲ្យរាំរបាំខ្លះ នៅទីធ្លា ដើម្បីជាកិត្តិយសដល់គណៈប្រតិភូ រួចទើបអ្នកស្រីចាងហ្វាងនាំទៅបង្ហាញបន្ទប់ដំណេកនិងបន្ទប់បាយសំរាប់កុមារទាំងឡាយនេះ ។ ខ្ញុំសង្កេតឃើញថា កុមារចិនច្រើនមានព្រលឹងនឹងសាច់ឈាមធាត់ទ្រលុប ទឹកមុខស្រស់ញញឹមនឹងឫកពាស្វាហាប់ដោយឥតមានអៀនអៀមអ្វីឡើយ ។

២ - ស្ពានមួយយ៉ាងធំនិងយ៉ាងវែងដែលឆ្លងកាត់ទន្លេ យ៉ង់-ត្សេ-ក្យាង ស្ពាននេះមានពីរផ្នែក: ថ្នាក់ក្រោមសំរាប់រថភ្លើង ឯថ្នាក់លើសំរាប់រថយន្តនិងចរាចរធម្មតា រួចមានបន្ទប់មួយដ៏ស្អាតសំរាប់ទទួលភ្ញៀវ ប្រជាជនចិនមានមោទនភាពនឹងស្ពាននេះយ៉ាងច្រើនដោយហេតុថា តាំងពីយូរណាស់មកហើយ គេចង់បានស្ពានមួយ ដើម្បីឆ្លងកាត់ទន្លេដ៏ធំនេះ តែរដ្ឋាភិបាល ជាង-កាយ-ជៀក គ្មានមធ្យោបាយនឹងសង់កើត ទាល់តែរដ្ឋាភិបាលចិនថ្មីទើបអាចសង់បាន ដោយចំណាយពេលយ៉ាងខ្លីនឹងចំណាយលុយយ៉ាងតិច ។

៣ - រោងចក្រធ្វើគ្រឿងបរិក្ខារផ្សេង ៗ ។

កិច្ចការទាំងឡាយនៅស្រុកចិននាបច្ចុប្បន្នកាលនេះ ច្រើនតែធ្វើឡើងដោយប្រណាំងប្រជែងគ្នា ដូច្នេះនៅក្នុងរោងចក្រនីមួយ ៗ គេច្រើនឃើញមានរូបថតនៃកម្មករគំរូ ចំពោះរោងចក្រក៏មានការប្រណាំងប្រជែងដូចនេះ ដោយរាជការខេត្ត ឬរដ្ឋាភិបាលកណ្តាលមានចែកជាសញ្ញាប័ណ្ណ សម្រាប់រោងណាដែលបានលទ្ធផលប្រសើរ ។

៤ សាលាមធ្យមសិក្សា :

កំណត់ពេលសិក្សាចិនដូចនេះ បឋមសិក្សា ៦ឆ្នាំ មធ្យមសិក្សា ៦ឆ្នាំ គិតទៅកំណត់ពេល ១២. ឆ្នាំ ទើបបានចូលឧត្តមសិក្សា តែឥឡូវនេះ, រដ្ឋាភិបាលចិនគិតបន្ថយមកត្រឹម ១០ឆ្នាំ ។ គេបានធ្វើការ

ពិសោធន៍កម្មវិធីថ្មីនេះ នៅអាគារសិក្សាខ្លះហើយ សូមមិត្តជ្រាបថា របៀបចិនសម័យនេះ មានធ្វើការពិសោធន៍ ការអនុវត្តន៍និងការហត្ថកម្មយ៉ាងច្រើនបរិបូណ៌ ៗ នៅគ្រប់អាគារសិក្សាដែលបានទស្សនា ខ្ញុំតែងមានឃើញគ្រឿងបរិក្ខារយ៉ាងគ្រប់គ្រាន់សំរាប់ធ្វើការពិសោធន៍ខាងផ្នែកវិទ្យាសាស្ត្រ ៗ តាមសង្កេតឃើញថា គ្រឿងបរិក្ខារក្នុងមធ្យមសិក្សាអស់ទាំងនេះសម្បូរជាងនៅប្រទេសបារាំង កាលពេលជំនាន់ខ្ញុំទៅសិក្សា ៗ ក្រៅពីបន្ទប់សំរាប់ពិសោធន៍នេះ មានបន្ទប់ខ្លះទៀត សំរាប់ការហត្ថកម្មនៅពេលចេញលេងសិស្សខ្លះបានធ្វើការហាត់ប្រាណតាមបង្អាក់ក្មេង ៗ សូមជំរាបមិត្តថានៅមធ្យមសិក្សា គេឥតមានដាក់កៅអីសម្រាប់សាស្ត្រាចារ្យ ឡើយក្នុងបន្ទប់រៀន ៗ

៩-រោងចក្រស្វូដែក :

រោងចក្រនេះមានទំហំដីធំយ៉ាងក្រៃលែង កម្មករទាំងអស់មានចំនួន១០០.០០០នាក់ នឹងច្រើនតែរស់នៅក្នុងគ្រឹះស្ថាន ដែលរដ្ឋាភិបាលសង់សំរាប់ សព្វថ្ងៃនេះ ទីក្រុងចិនច្រើនពុំទាន់មានទេសភាពស្អាតល្អនៅឡើយ ព្រោះរដ្ឋាភិបាលពុំទាន់បានយកចិត្តទុកដាក់ ដោយគិតតែពីស្ថាបនារោងចក្រនិងគ្រឹះស្ថានថ្មីៗ ទៀតសម្រាប់កម្មករ ៗ

នៅយប់ថ្ងៃ ២៨តុលា វេលាម៉ោង២១គណៈប្រតិភូបានចាកចេញក្រុង "វូ-ហាន់" ដើម្បីជិះរថភ្លើងឆ្ពោះទៅរដ្ឋធានី "ប៉េកាំង" លើកនេះតាមផ្លូវដំណើរ ច្រើនមានទេសភាពជាវាល, នៅចំការអ្នកស្រុកច្រើនធ្វើការជុំគ្នា ៗ ជួនកាលនៅចំពោះមុខក្រុមអ្នកធ្វើការ គេឃើញដោតទង់ក្រហម នេះគឺជាកម្មករស្ម័គ្រចិត្តដែលមកជាជំនួយដល់កសិករៗ នៅយប់ថ្ងៃ២៩ តុលា វេលាម៉ោង២១ ទើបបានរថភ្លើងមកដល់ក្រុង "ប៉េកាំង" ៗ

ដល់រដ្ឋធានី "ប៉េកាំង" រដ្ឋាភិបាលចិនបានឲ្យនៅជាប់ជាមួយនូវនាងមួយរូប ដែលចេះបកភាសាខ្មែរ ចំណែកអ្នកបកភាសាជាបារាំង ក៏ត្រូវត្រឡប់ទៅក្រុងកាំង-ចូវវិញ ដោយពជការខេត្តនេះត្រូវការជាចាំបាច់ ៗ នាងបកភាសាក្រោយនេះនិយាយខ្មែរយ៉ាងច្បាស់លាស់ និងចេះពាក្យវប្បធម៌ថ្មីៗជាច្រើន ៗ ខ្ញុំបានសាកសួរទៅ នាងនេះប្រាប់ថានាងកើតនៅស្រុកខ្មែរ ទើបតែទៅរៀនសូត្រនាស្រុកចិនក្នុងកម្លុង ២ឆ្នាំប៉ុណ្ណោះ ។ នាងនឹងធ្វើដំណើរជាមួយរហូតដល់គណៈប្រតិភូចាកចេញពីប្រទេសចិនប្រជាមានិត ក្នុងរយៈសំណាក់នារដ្ឋធានី "ប៉េកាំង" គណៈប្រតិភូបានទស្សនា :

១-វាំងវស្សាន្តរដូវនៃព្រះអធិរាជ :

វាំងនេះមានទំហំដ៏ធំទូលាយព្រមទាំងនៅក្នុងកំពែងមានបឹងមួយដ៏ធំ សំរាប់ព្រះអធិរាជគង់ទូកកំសាន្ត ។ ឥឡូវនេះប្រាសាទទាំងឡាយក្នុងវាំង បានទៅជាសារមន្ទីរ ។

២-ព្រះបរមរាជវាំងនៃព្រះអធិរាជដែលពាក្យថាវាំងមានឈ្មោះថា«ក្រុងហាមប្រាម» តាមសង្កេតឃើញថា ប្រាសាទចិនទាំងឡាយច្រើនមានរាងទីង ក្បាច់ដូចៗគ្នា សសរ ទ្វារ ទីងគ្រឿងដំបូលច្រើនធ្វើអំពីឈើ ។

៣-ពិពណ៌ផលិតផលខាងផ្នែកកសិកម្ម:

នៅក្រុងធានី នីមួយៗ រដ្ឋាភិបាលច្រើនសង់គ្រឹះស្ថានមួយដ៏ស្ដុកស្ដម្ភ សម្រាប់តាំងផលិតផលផ្សេងៗ ដ៏ប្រសើរ ដែលខេត្តនីមួយៗបានបង្កើតឡើង នៅកន្លែងពិព័ណ៌ដែលខ្ញុំបានទស្សនានេះឃើញថាប្រទេសចិនបានចំរើនយ៉ាងជាក់ស្ដែងមែននៅផ្នែកសិកម្ម ជ្រូកមួយធំស៊ើនឹងកូនគោ តាមខ្ញុំសួរថាជ្រូកនេះទម្ងន់រវាង៥០០គ.ក ជ្រូកនេះពុំមានយកមកតាំងទាំងនៅរស់ទេ គឺគ្រាន់តែយកស្បែកវាមកញាត់ចំបើង។ស្មៅ ។ ត្រឡាច ស្រស់ ល្ពៅ ស្ពៃក្ដោបដ៏ធំៗសម្បើម លើកនេះផ្លែឈើពិត ១ តែមួង ។ល។ ម្យ៉ាងទៀតប្រជាជាតិចិន ច្រើនមានការប៉ិនប្រសប់ចម្រាញ់ប្រេងពីស្នូលពោត យកចំបើងទៅធ្វើគ្រឿងប្រដាប់ប្រដា ខ្លះសម្រាប់ប្រើប្រាស់ ។ល។

៤-សាលាបច្ចេកទេសចំរុះ ធិញ-ព៉ះ

សាលានេះជាសាលាមួយដ៏ល្បីល្បាញនៃប្រទេសចិន សិស្សទាំងអស់មានចំនួន ១០០០០នាក់ នឹងមានសិស្សបរទេសខ្លះនៅរៀនទីនេះដែរ ។ នៅអាគារនេះ គណៈប្រតិភូបានទស្សនា ខួរអេឡិចត្រូនិក កន្លែងពិសោធន៍ផលគតិវិទ្យា យន្តសាស្ត្រអនុវត្ត ។

៥-ព្រះវិហារសំរាប់បួងសួង

មួយឆ្នាំម្ដងៗ ព្រះអធិរាជស្ដេចយាងមកទីនេះដើម្បីបួងសួងសូមឱ្យបានផលដំណាំល្អ កំពែងមូលធ្វើពីថ្មដ៏មានកាំរវាង៩០ម. ព័ទ្ធព្រះវិហារ ។ ហេតុចំឡែកមានដូចនេះ អ្នកមួយនិយាយតិចៗ ផ្ទាល់នឹងកំពែង ឯអ្នកឯទៀត ដែលនៅឆ្ងាយពីនេះកាលណាយកត្រចៀកផ្ទាល់នឹងកំពែង អាចឮយ៉ាងច្បាស់នូវសំដីនេះ ។



៦-សាលាប៉ុំទីងត្បូងត្រិះ

រយៈពេលរៀនមានកំណត់៩ ឆ្នាំ ដោយរើស

យកក្មេងចូលតាំងពីអាយុ ៨ ដល់១៩ ឆ្នាំ ការហាត់កាយវិការ ដើម្បីហាត់លោតនឹងឲ្យទន់ភ្លន់មានលំនាំដូចជាសៀក ៗ ដើម្បីជាកិត្តិយសដល់គណៈប្រតិភូសិស្សានុសិស្សបានស្តែងនូវចំណេះរបស់ខ្លួនខ្លះដូចតទៅនេះ ៖

- របៀបហាត់លោតផ្ទោះនៃសិស្សថ្នាក់ទី ១
- ក្រុមនារីថ្នាក់ទី ២ រាំជាពួក
- របៀបហាត់អានអត្ថបទនៃសិស្សថ្នាក់ទី ២
- សិស្ស ២ នាក់នៃថ្នាក់ទី ២ បានស្តែងរឿងមួយភាគ
- នារី ២ នាក់នៃថ្នាក់ទី ២ បានស្តែងរឿងមួយភាគ

ក្នុងរឿងដែលបានស្តែងនេះ គេធ្វើក្បួននឹងកាយវិការឲ្យបានសមតាមតួអង្គ ៗ

- ស្តែងភាគបំបាំងលើគោកក្នុងទឹកនៃក្រុមសិស្សថ្នាក់ទី ៧ គ្រាន់តែភាគបំបាំងនេះ មានដំណើរអស់រយៈពេលរាង់មួយម៉ោង ដោយអ្នកដើរតួទាំងឡាយឥតមានបញ្ចេញសំដីអ្វីមួយម៉ាត់ សំរាប់ភាគនេះ មានសិស្សប្រគំភ្លេងទាំងអស់ចំនួន ២០ នាក់ ៗ

៧-ប្រជាសហគម :

សម័យនេះនៅនាជនបទស្រែចំការ រដ្ឋាភិបាលចិនបានប្រមូលផ្តុំសហគមនៅនាទីខ្លះទៅជាប្រជាសហគម ដែលអាចបង្កើតផលនឹងមានសង្គមកិច្ចដោយខ្លួនឯងសឹងគ្រប់ផ្នែក ៗ ប្រជាសហគមនីមួយៗ មានកន្លែងចិញ្ចឹមទារក សួនកុមារ សាលារៀន មន្ទីរពេទ្យ កន្លែងចិញ្ចឹមជនចាស់ជរា រោងជួសជុលគ្រឿងម៉ាស៊ីនផ្សេង ៗ សំរាប់សមាជិក ៗ ល ៗ សមាជិកទាំងឡាយធ្វើការជាប់មុខគ្នា នឹងទទួលបៀវត្សតាមផលនឹងតាមការ ដែលខ្លួនធ្វើ ៗ ម្យ៉ាងទៀត គេច្រើនទទួលបាយនៅភោជនីយដ្ឋានសាធារណៈៗ នៅប្រជាសហគមនាជាយក្រុងប៉េកាំង គេបាននាំគណៈប្រតិភូទៅទស្សនា កន្លែងថែទាំចាស់ជរា កន្លែងដាំបន្លែនឹងផ្កាក្នុងបន្ទប់កញ្ចក់ នឹងកន្លែងចិញ្ចឹមជ្រូកមាន់ទា ៗ

៨-កំពែងធំ :

កំពែងធំដែលមានឈ្មោះល្បីក្នុងសាកលលោក នៅចម្ងាយពីប៉េកាំង ចំនួន ៧០គ.ម ៗ ជិតទៅដល់គេចាប់អារម្មណ៍ នឹងទេសភាពខ្សែភ្នំហួតហែងជាប់ស្រយាល កំពែងធំនេះសង់តាមលើភ្នំនឹងបន្ទោះភ្នំជាច្រើនសតវត្សមកហើយ ដើម្បីការពារសត្រូវ ៗ តាមនាទីបកភាសា កំពែងនេះមានកំពស់៩ម ទទឹង៥ម. នឹងបណ្តោយ ៣០០០គ.ម. បើជាមានកំពស់តែ១ម. នឹងទទឹង ១ម កំពែងនេះ

គាបរុំព័ទ្ធជុំវិញ ផែនដីយើងបាន ៗ តាមលើកំពែងគេមានទុកជាប្រហោង ។ សំរាប់បាញ់សត្រូវខាងមានជាប៉មនៅចន្លោះរវាង ២០០ម ជាលំដាប់ មានគណៈប្រតិភូឯទៀត ជាច្រើនបានទៅទស្សនានៅថ្ងៃជាមួយនោះនឹងបានដើរកំសាន្តលើកំពែងធំនេះ ។

៩_ម៉ុងព្រះរាជវង្ស "មិញ"

តាមផ្លូវត្រឡប់ពីកំពែងធំមកកាន់ក្រុងប៉េកាំង គណៈប្រតិភូបានឈប់ទស្សនាផ្នូរនៃព្រះរាជវង្សមិញដែលមានទាំងអស់ ១៣ សង់នៅត្រង់បង្កើះភ្នំឆ្ងាយដាច់ៗ ពីគ្នា ។ តាមសងខាងផ្លូវចូលទៅផ្នូរនីមួយៗ គេមានតម្រៀបនូវសត្វផ្សេងៗ ដំរី សេះ អូដ្ឋ លា ។ល។ នឹងសស្សរជនសំខាន់នៃព្រះរាជអាណាចក្រដែលឆ្លាក់អំពីថ្ម នៅជិតផ្លូវតែងមានព្រះវិហារឥតជញ្ជាំងមួយសំរាប់បាំងគ្រប់នូវជុំថ្មបួនជ្រុងទ្រវែងមួយដែលមានឆ្លាក់ព្រះនាមនៃព្រះអធិរាជ ។ គណៈប្រតិភូបានទស្សនា តែម៉ុងមួយដែលទើបជីករកឃើញក្នុងគ្រិស្តសករាជ ១៩៥៦ ឯម៉ុង ១២ ទៀតដែលឥតទាន់ជីកនៅឡើយគ្រាន់តែឃើញអំពីចម្ងាយប៉ុណ្ណោះ ។ ត្រង់ផ្នូរនីមួយ ៗ គេឃើញមានព្រៃស្រល់យ៉ាងសាខា គួរជាទីចាប់អារម្មណ៍ ។ គណៈប្រតិភូ បានចុះតាមជណ្តើរដែលទើបសង់ឡើងចំនួន ២៥ម ទៅក្នុងដី រួចទើបចូលតាមខ្លោងទ្វារថ្មមួយដែលគេទើបបោះ ព្រោះដើមឡើយក្រោយដែលបញ្ចុះក្តារមឈូស គេមានផ្សារជិត ទើបមានរូងមួយខ្ពស់ទូលាយ ដែលតាមនោះគេមានឃើញផើងប្រេង២ដ៏ធំសំរាប់ដុត ផើងប្រេងក្រអូប១ (ផើងទាំងនេះសុទ្ធតែមានសំណល់ប្រេង) ព្រះរាជបល្ល័ង្គនឹងប្រដាប់ផ្សេងៗទៀត ។ល។ ដើរតាមរូងនេះឆ្ងាយបន្តិចទៅ ទើបដល់ខ្លោងទ្វារឈើមួយដែលសម្រាប់បិទបាំង បញ្ចុះមឈូសហិបឈើទាំងឡាយ ដែលសម្រាប់ដាក់ប្រដាប់ប្រដាប្រើប្រាស់និងក្តារមឈូសសុទ្ធសឹងពុកអស់រលីង ។ តែសព្វថ្ងៃគេបានដាក់ហិបថ្មីនឹងមឈូសថ្មី ត្រង់កន្លែងដូចដើម ហិបនឹងមឈូសថ្មីគ្មានចំណុះអ្វីទេ ព្រោះប្រដាប់នេះទាំងប៉ុន្មាន គេបានរៀបចំតាំងនៅគ្រឹះស្ថាន ២ដែលសង់ឡើងនៅតាមសងខាងផ្លូវមកកាន់ម៉ុង) នៅទីនេះគេឃើញមានមឈូស៣ គឺមួយបញ្ចុះព្រះអធិរាជនឹងពីរទៀត សម្រាប់ព្រះអគ្គមហេសី ។ តាមគ្រោងការព្រះអគ្គមហេសីទាំងពីរត្រូវបញ្ចុះនៅរូងដោយឡែកដែលនឹងស្ថាបនាតភ្ជាប់នឹងនៅសងខាងនៃរូបព្រះ តែដោយពេលនោះមានវិបត្តិក្នុងប្រទេសនឹងដោយការបះបោរនៃកម្មករ រូងសងខាងទាំងពីរ ក៏ពុំបានសង់ឲ្យហើយស្រួលបួល ដូច្នេះហើយមឈូសព្រះអគ្គមហេសីទាំងពីរបញ្ចុះក៏

រួមជាមួយគ្នានឹងរូបព្រះអង្គទៅ ។ នៅពេលត្រឡប់ចេញពីផ្សារមក គណៈប្រតិភូក៏បានទស្សនាគ្រឹះស្ថានមួយដែលដាក់តាំង វត្ថុរើចេញពីហាបផ្នូរ នៅទីនោះខ្ញុំសង្កេតឃើញមានប្រដាប់ព្រះអលង្ការ សក់ព្រះអធិរាជដុំមាសជាច្រើនសម្រាប់លុយជំនាន់នោះនឹងវត្ថុតម្លៃៗឯទៀតជាច្រើន គ្រឹះស្ថានមួយទៀតដែលនឹងតាំងវត្ថុនៃព្រះអគ្គមហេសីពុំទាន់បើកទ្វារឲ្យចូលនៅឡើយ ដោយអ្នកបច្ចេកទេសគេកំពុងរៀបចំពិធីតាំងវត្ថុឲ្យបានស្រួល ។ ខ្ញុំសរសើរដល់រដ្ឋាភិបាលដែលរៀបចំតាំងវត្ថុ ដ៏មានតម្លៃទាំងនេះនៅក្នុងដាច់ស្រយាលពីទីប្រជុំជន ដោយឥតខ្លាចចោរកម្ម ។ តាមផ្លូវត្រឡប់មកវិញឡាននៃ គណៈប្រតិភូបានបើកបរលើទំនប់មួយដ៏ធំល្អ ស្ថាបនាដោយកម្មករស្ម័គ្រចិត្ត ។

១០–សាលាតូរ្យតន្ត្រី និងចម្រៀង :

នៅគ្រឹះស្ថាននេះ សិស្សសិក្សាខាងផ្នែកតូរ្យ-តន្ត្រីចិននិងបរទេស រយៈពេលរៀនមានកំណត់ ១៣ឆ្នាំ និងជ្រើសរើសឲ្យចូលចាប់តាំងពីអាយុ៩ ឬ ១០ឆ្នាំដើម្បីជាកិត្តិយសដល់គណៈប្រតិភូ :

–សិស្សចំនួន ៥០ នាក់ ដែលអាយុមធ្យម ១៤ឆ្នាំ នឹងដែលប្រដាប់ដោយគ្រឿងភ្លេងផ្សេងៗ បានប្រគុំបទដែលរៀបដោយលោក „ ប៊ុ. សេរ „ ជនជាតិបារាំងមួយបទពិរោះ ក្នុងពេលប្រគុំបទភ្លេងខ្ញុំចូលចិត្តគយគន់កាយវិការ មេដែលត្រូវឲ្យសង្វាក់ដល់ក្រុមប្រដាប់ភ្លេងនីមួយៗ ក្នុងពេលប្រគុំ ។

–កញ្ញាម្នាក់ដែលមានប្រដាប់ភ្លេងបូរាណចិនបន្ទរតាមបានពោលកំណាព្យពីរៈ កំណាព្យជោគជ័យជំពោះលោកប្រធានម៉ៅ នឹងកំណាព្យគង្វាលចៀម ។

១១–សារមន្ទីរនៃដំណើរបដិវត្ត :

សារមន្ទីរនេះមានតែងតាំងរូបថត ឯកសារ វត្ថុផ្សេងៗទាំងឡាយនៃប្រទេសចិនចាប់តាំងពី គ.ស ១៩២១ រហូតដល់រូបចំបាំងកូរេ មានផ្ទាំងផែនទីឧទ្ទិន្នភាពជាច្រើន ដែលប្រដាប់ដោយពន្លឺចង្កៀងមានពណ៌ផ្សេងៗបានចែងចាំង សម្រាប់ពន្យល់នូវដំណើររឿងហេតុ ខ្ញុំបានប្រទះឃើញមានផ្ទាំងផែនទី ឧទ្ទិន្នភាពជាច្រើន នៅគ្រប់គ្រឹះស្ថានសិក្សាទាំងឡាយដែលគណៈប្រតិភូបានធ្វើទស្សនកិច្ច នេះជាគុណប្រយោជន៍មួយខាងផ្នែកសិក្សាភូមិសាស្ត្រ ។

១៤–សារមន្ទីរនៃពង្សាវតារ :

សារមន្ទីរនេះមានតែងតាំងចាប់ពីវត្ថុ បរមបូ. ពណ ដែលគេបានគាស់កកាយរកឃើញរហូតដល់ពង្សាវតារនៃសម័យបច្ចុប្បន្នកាល គេបានរៀបចំតាំងហួរហែជាលំដាប់តាមសតវត្ស នៅទីនោះបាន

បញ្ជាក់ថាៈ

–ជនជាតិចិនរកឃើញត្រីវិស័យមានរទេះ ឈើមួយ ទីនឹមនុស្សឈើមួយដែលមានម្រាមមួយ ចង្អុលទៅទិសខាងជើង ទុកជារទេះបត់បែរយ៉ាងណា ម្រាមនៃមនុស្សឈើលើរទេះនៅតែចង្អុល ទិសខាង ជើង ។

–ជនជាតិចិនរកឃើញក្រដាស

–ជនជាតិចិនរកឃើញចំនួន (១,១៤១៦)

១៣–វត្តសុគា :

វត្តសុគានេះ ជាគ្រឹះស្ថានមួយដ៏ស្កុតស្កម្ភយ៉ាង ក្រៃលែងដែលស្ថាបនាឡើង ដោយចំណាយពេល ខ្ទឹតគន្លឹតតែកំឡុង ១០ខែប៉ុណ្ណោះ កន្លែងអង្គុយមាន បីថ្នាក់ទីងអាចទទួលមនុស្សបាន ១០.០០០នាក់ ។ នៅជាប់ជាមួយមានបន្ទប់មួយយ៉ាងធំទូលាយសំរាប់ ពិធីជប់លៀងទីងមានបន្ទប់ឯទៀតៗច្រើន សម្រាប់ សំរាកដែលតុបតែងវចនាឡើងដោយខេត្ត នីមួយៗ គំពលសុទ្ធតែក្រាលដោយថ្មមថ្មយ៉ាងរលោង បើ មិនប្រយ័ត្នច្បាស់ជារអិលពុំខាន ។

នៅវដ្តជាទី ប៉េកាំង គេបានប្រទះឃើញគ្រឹះ-ស្ថានសាធារណៈដ៏ស្កុតស្កម្ភជាច្រើន គណៈប្រតិភូ បានចាកចេញវដ្តជាទីនេះនៅថ្ងៃ ១០ វិច្ឆិកា ពេល ម៉ោង១២ ដើម្បីឆ្ពោះទៅ «ណាង.កាំង» ក្រុមយើង ខ្ញុំមានសេចក្តីរីករាយម្យ៉ាងដែរ ត្រឡប់ចុះមកផ្នែក ប្រទេសចិនខាងត្បូង ដោយវដ្តជាទីមានអាកាសត្រ-ជាក់ជាលំដាប់ នៅពេលនោះមានដល់ទៅសូន្យ អង្សា តាមនាងបកកាសាថាដល់ទៅខែ១ឬ ២ទឹកខ្វះ នៅវដ្តជាទីទឹកកកវូប មានប្រជាជនមករអិលលេង ជាកំសាន្តនៅទីនោះ កាលមកកាន់ក្រុងប៉េកាំងវិញ. ក្មួងបានឆ្លងទន្លេ «យ៉ាងត្សេក្យាង» តាមស្ពានធំ ដែលបានរៀបចប់នៅខាងលើ ផ្លូវនេះដល់ត្រឡប់ចុះទៅវិញបានឆ្លងដោយនាវា រដ្ឋាភិបាលបាន គ្រោងការទឹងស្ថាបនាស្ពានមួយត្រង់កន្លែងនេះរួចជា ស្រេច វថក្មួងបានដល់ក្រុងណាង.កាំង ។

(នៅមានត)

ដំណឹងចុងក្រោយបង្អស់



# មិត្តយោបនេះ ថា...

## សាស្ត្រាចារ្យជំនាន់ ១៩៦០ ខាតអស់ ៣ ខែ ក្នុងការតែងតាំង

---

សមាជិកមួយចំនួន បានឲ្យដំណឹងមកសមាគម ថាសាស្ត្រាចារ្យបឋមភូមិជំនាន់ ១៩៦១ បានត្រូវតែងតាំងចាប់ពីកាលបរិច្ឆេទដែលខ្លួនប្រឡងជាប់ទៅ គឺចាប់តាំងពីថ្ងៃ ២៧ មិនា ១៩៦១ តាមព្រះរាជក្រឹត្យ លេខ518 CE ចុះថ្ងៃ ៧ តុលា ១៩៦១។ ចំណែកឯបៀវត្ស និងឋានន្តរស័ក្តិ ក៏គិតពីពេលនោះដែរ ។

ដំណឹងខាងលើនេះ បានធ្វើឲ្យបណ្ដាសាស្ត្រាចារ្យបឋមភូមិជំនាន់១៩៦០ មានសេចក្ដីងឿងឆ្ងល់យ៉ាងក្រៃលែង ។ ងឿងឆ្ងល់ ត្រង់ដែលខ្លួនពុំបានតែងតាំងពីថ្ងៃ ដែលខ្លួនប្រឡងជាប់ (២១មិនា ១៩៦០) បែរជាទទួលការតែងតាំងចាប់ពីថ្ងៃ ១ កក្កដា ១៩៦០ គឺថ្ងៃដែលខ្លួនទទួលលិខិតបង្គាប់ចេញប្រតិបត្តិការបង្រៀន (prise de service) ទៅវិញ ។ គិតទៅខាតអស់ ៣ខែ ១០ថ្ងៃទទេ ។

កន្លែងនេះ យើងក៏ពុំយល់ដែរ ។ សាស្ត្រាចារ្យបឋមភូមិជំនាន់ ១៩៦០ និងជំនាន់ ១៩៦១ បានរៀនសូត្រកម្មវិធីក្នុងរយៈពេលដូចគ្នា ក្នុងវិទ្យាស្ថានដូចគ្នា មានក្របខ័ណ្ឌដូចគ្នា ម្ដេចក៏របៀបតែងតាំងខុសគ្នាទៅវិញ ។ បើថាសាស្ត្រាចារ្យជំនាន់ ១៩៦០ បានប្រឡងជាប់ចេញ មុនថ្ងៃចេញក្រឹត្យតែងតាំងក្របខ័ណ្ឌ (Kret de création de cadre) គឺថ្ងៃ ២៧ កញ្ញា ១៩៦០ ម្ដេចក៏តែងតាំងសាស្ត្រាចារ្យទាំងនេះ ចាប់ពីថ្ងៃ ១ កក្កដា១៩៦០ មុនក្រឹត្យជិតទៅ៣ខែបាន? បើបានជាតែងតាំងមុនក្រឹត្យ៣ខែបាន ម្ដេចក៏មិនតែងតាំងមុន ៦ខែឲ្យគ្នាតែម្ដងទៅ គឺចាប់តាំងពីថ្ងៃប្រឡងជាប់ ដូចជាសាស្ត្រាចារ្យជំនាន់១៩៦០ឬដូចជាអធិការបឋមសិក្សាដែលធ្លាប់តែបានតែងតាំងចាប់ពីថ្ងៃប្រឡងជាប់ភ្លាម

ក្នុងការលើកបញ្ហានេះមកចោទ សាស្ត្រាចារ្យជំនាន់ ១៩៦០ គ្មានទឹកឃើញចង់ច្រណែន ឬមានឆន្ទៈសង្ស័យអ្វីទៅលើមិត្តថ្មីជំនាន់ ១៩៦១ ទាល់តែសោះ ។ ព្រោះដឹងច្បាស់ថា ការតែងតាំងមិត្តទាំងនោះជាការត្រឹមត្រូវពិតប្រាកដ ។ ប៉ុន្តែ

សាស្ត្រាចារ្យចំនួនជាង ៥០ នាក់ ជំនាន់ ១៩៦០ ត្រូវខាតប្រយោជន៍ខ្លួន ព្រោះតែតែងតាំងយឺត ៣ ខែ ១០ ថ្ងៃ គឺខាត:

១) ម៉្យាងប្រាក់បំណាច់នឹងប្រាក់ឈ្នួលផ្ទះ ប្រមាណជិតមួយម៉ឺនរៀលម្នាក់ ,

២) ម៉្យាងទៀត ខាតរយៈពេលដែលត្រូវបង្គ្រប់ឡើងឋានន្តរសក្តិ ខ្លះត្រឡប់ជាមកចាំឡើងជាមួយមិត្តជំនាន់ ១៩៦១ ទៅវិញ ។ ក្នុង ១ ២ នេះ គឺសាស្ត្រាចារ្យជំនាន់ ១៩៦០ ទាំងអស់គ្នា ត្រូវខាត ។

ចំពោះបញ្ហានេះ "សមាគមសាស្ត្រាចារ្យខ្មែរ" យើង ក៏មានមតិស្របតាមសេចក្ដីងឿងឆ្ងល់របស់សមាជិកខាងលើនេះដែរ ។ សមាគមចង់ដកស្រង់មតិពីបណ្ដាសមាជិកដទៃទៀត ជាពិសេសគឺពីសាមីជនទាំងឡាយប្រយោជន៍នឹងតាក់តែងវិធីទៅស្នើនឹងក្រសួងមានសមត្ថកិច្ចក្នុងពេលខាងមុខនេះ ។ សូមមិត្តសមាជិកជួយមតិឲ្យបានគគុះគរ !

## សូមមតិ

«ទស្សនាវដ្ដីសាស្ត្រាចារ្យ» យើង ចេញបានប្រាំលេខហើយ ។

សូមមិត្តជួយរួមប្រស្រ័យលំអផង ដោយបញ្ចេញមតិចំពោះអត្ថបទ ដែលបានផ្សាយរួចមកហើយ (ពេញចិត្តត្រង់ណា មិនពេញត្រង់ណា គួរសរសេរយ៉ាងណាវិញ) នឹងស្នើប្រធានផ្សេង ៗ ទៀត ដែលមិត្តយើងយល់ថាមានសារៈសំខាន់រួម ។

ដោយសេចក្ដីសង្ឃឹម

# ជីវភាពមិត្តយើង

## ស្មារតីឈឺឆ្អាលរបស់សមាជិកនៅខេត្ត

ដោយមានសមាជិកជាច្រើននៅខេត្ត បាន ផ្ញើសំបុត្រមកគណៈកម្មាធិការនាយក សូមឲ្យតវ៉ាចំពោះ ក្រសួងមានសមត្ថកិច្ចដើម្បីការពារផលប្រយោជន៍សាស្ត្រាចារ្យយើង ក្នុងរឿងផ្លាស់ លោក ទី - អុល កណ្ដាលឆ្នាំសិក្សា គណៈកម្មាធិការនាយកបានចាត់គ្នា ឲ្យទៅសាកសួររកខុសត្រូវព្រមទាំងជូនញត្តិ ១ច្បាប់ ទៅឯ·ឧ· រដ្ឋមន្ត្រីក្រសួងអប់រំជាតិរួចទៅហើយ (សូមអានត្រង់ផ្នែកប្រអប់សំបុត្រក្នុងទស្សនាវដ្ដីលេខនេះ) ។ ប៉ុន្តែសំបុត្រពីខេត្ត បេះតែមកដល់បន្តបន្ទាប់គ្នាទៀត យើងអត់ទ្រាំមិនដកស្រង់ខ្លះ មកចុះក្នុងទស្សនាវដ្ដីពុំបាន ពីព្រោះសំបុត្រទាំងនេះសុទ្ធតែសំដែងការមូលមតិគ្នារវាងសមាជិក ក្នុងការឈឺឆ្អាលការពារមិត្ត និងការពារសិទ្ធិប្រយោជន៍ដំណែងរបស់ខ្លួន ។

**សាស្ត្រាចារ្យ ១៣រូប នៅវិទ្យាល័យខេត្តសៀមរាប** បានសរសេរមកថា : "...លោក ទី- អុល សាស្ត្រាចារ្យនៅសាលាវិចិត្រសិល្បៈ ទីក្រុងភ្នំពេញ បានត្រូវផ្លាស់ចេញ ពីកន្លែងធ្វើការរបស់លោក ដែលកំពុងប្រព្រឹត្តទៅក្នុងសេចក្ដីចំរើន ។ ដំណឹងនេះ នាំឲ្យញាប់ញ័រដល់សតិអារម្មណ៍យើងខ្ញុំជាខ្លាំង ចំពោះបញ្ហាផ្លាស់បុគ្គលិកកណ្ដាលឆ្នាំសិក្សាដូច្នេះ ព្រោះតម្លៃនៃសាស្ត្រាចារ្យម្នាក់ៗ ជាតម្លៃនៃសាស្ត្រាចារ្យទាំងអស់ ដែលរួមរស់នៅក្រោមម្លប់នៃដំបូលសមាគមជាមួយគ្នា ។ តើគណៈកម្មាធិការ នៃសមាគមសាស្ត្រាចារ្យយើង បានចាត់វិធានការដូចម្ដេចខ្លះ ? ។ យើងខ្ញុំបារម្ភក្រែងមានប៉ះពាល់ដល់កិត្តិយសនៃសមាជិក សមាគមយើង ព្រោះយើងខ្ញុំតែងតែជួយគាំទ្រតម្លៃនេះជាដរាប..." ។

**សាស្ត្រាចារ្យ ១៤រូប នៅវិទ្យាល័យកំពង់ចាម** បានបញ្ជាក់ច្បាស់ក្នុងសំបុត្រថា : " .ដោយគិតដល់ការធានារ៉ាប់រងសិទ្ធិ ក្នុងការប្រកបមុខងាររបស់សាស្ត្រាចារ្យម្នាក់ៗ យើងខ្ញុំសូម

ឲ្យលោកប្រធានចាត់វិធានការដ៏មុឺងម៉ាត់ ធ្វើអន្តរាគមន៍ក្នុងរឿងនេះដើម្បីឲ្យលោកទីវ-អុលទៅប្រកបការងារនៅកន្លែងដដែលវិញ ហើយនិងទប់ទល់កុំឲ្យមានអំពើបែបនេះ កើតឡើងបានទៀតទៅអនាគត ស្របតាមគោលបំណងការពារសិទ្ធិនិងផលប្រយោជន៍នៃសមាជិក របស់សមាគមយើង ។

យើងខ្ញុំសូមសំដែងការគាំទ្រដ៏ពេញទំហឹងចំពោះលោកប្រធាន និងគណៈកម្មាធិការនាយកសមាគម ក្នុងការបំពេញកិច្ចខាងលើនេះ . . ” ។

## ❀ សាស្ត្រាចារ្យនៅអនុវិទ្យាល័យព្រៃវែង

៩ រូបបានបញ្ចេញមតិយ៉ាងនេះថា: “... សូមស្នើមកគណៈកម្មាធិការនាយក សូមចាត់វិធានការទាក់ទងជាមួយក្រសួងមានសមត្ថកិច្ច ដើម្បីនឹងបានពត៌មានច្បាស់ អំពីរឿងផ្លាស់លោកសាស្ត្រាចារ្យ ទីវ-អុលនេះ . . . ” ។

## ❀ សាស្ត្រាចារ្យ២៥រូប នៅអនុវិទ្យាល័យស្ទួង (កំពង់ចាម)

បានសរសេរប្រាប់មកថា: “... យើងខ្ញុំមានសេចក្ដីទន្ទឹងខ្លាំងណាស់ សូមមិត្តប្រធានមេត្តាជួយតវ៉ាយ៉ាងមុឺងម៉ាត់ដល់រាជការមានសមត្ថកិច្ច ឲ្យខាងតែមិត្ត ទីវ-អុល ត្រឡប់ទៅកាន់ដំណែងជាសាស្ត្រាចារ្យ នៅសាលាជាតិខាងសិល្បនិងមុខរបរវិញ ដើម្បីឲ្យយើងខ្ញុំនៅសាស្ត្រាចារ្យទាំងឡាយបានក្ដីកក់ក្ដៅក្នុងការរក្សាសិទ្ធិ និងកិត្តិយសទៅអនាគត . . . ” ។

## ▪ សមាជិកយើងនៅខាងអនុវិទ្យាល័យព្រៃល្វា

ក៏បានសរសេរសំបុត្រមកគណៈកម្មាធិការនាយកមានសេចក្ដីប្រហែលៗ គ្នានឹងខាងលើនេះដែរ ។

គណៈកម្មាធិការនាយក សូមថ្លែងអំណរយ៉ាងជ្រាលជ្រៅចំពោះសមាជិក នៅខេត្តទាំងឡាយ ដែលបានយកចិត្តទុកដាក់នឹងគ្រោះថ្នាក់ដែលធ្លាក់លើរូបមិត្តម្នាក់ ។ ចំពោះរឿងនេះ គណៈកម្មាធិការនាយក យល់ស្របទាំងស្រុង ។ ម្យ៉ាង ការសំដែងសមានចិត្តចំពោះលោក សាស្ត្រាចារ្យ ទីវ-អុល ជាការលើកទឹកចិត្តមួយធំចំពោះសាមីខ្លួន នឹងជាការរឹតចំណងសាមគ្គីភាពរវាងសមាជិកក្នុងផ្ទៃសមាគម ។ ម្យ៉ាងទៀត ការដែលចាប់អារម្មណ៍ទៅលើសិទ្ធិប្រយោជន៍សាស្ត្រាចារ្យជាបញ្ហាមួយ គួរតែលើកមកពិចារណាឲ្យជាក់ច្បាស់ដែរក្នុងគ្រានេះ ។ ភ្នាក់ងារសាស្ត្រាចារ្យ

ជាភ្នាក់ងាររដ្ឋ កំពុងតែរីកចំរើន ដែលទទួលភារៈបង្ហាត់បង្រៀនសិស្សផ្នែកមធ្យមសិក្សា។ ករណីយកិច្ចរបស់សាស្ត្រាចារ្យ គឺអប់រំយុវជនឲ្យបានជាពលរដ្ឋល្អបេះដូង ដើម្បីកសាងប្រទេសជាតិទៅអនាគត ។ ប៉ុន្តែដើម្បីបំពេញករណីយកិច្ចនេះ សាស្ត្រាចារ្យ ក៏ត្រូវការឲ្យមានការធានាគ្រប់គ្រាន់ចំពោះសិទ្ធិនិងកិត្តិយសនៃវិជ្ជាជីវៈខ្លួន ។ ឯសិទ្ធិរបស់សាស្ត្រាចារ្យ គឺមានសេរីភាពគ្រប់គ្រាន់ក្នុងការតាក់តែងឯកសារបង្រៀន និងជ្រើសរើសវិធីតាមគោលនិយមរបស់ខ្លួន កុំឲ្យតែចេញក្រៅពីក្របខណ្ឌកម្មវិធីដែលគេកំណត់ឲ្យ ។ ក្នុងការបង្រៀនសាស្ត្រាចារ្យ ត្រូវការដកខ្លួនចេញឲ្យផុតពីទំលាប់ប្រចាំដែលៗ (routine) ដើម្បីបញ្ចូលចំណេះថ្មីទាន់សម័យដោយច្នៃរចនាការពន្យល់ឲ្យបានល្អ ។ ក្នុងការពន្យល់ លែងអ្វីនឹងដក់មាត់លើសខ្លះក្នុងពាក្យសំដី ? បើមានសិស្ស ឬ ពាង់ហ្វាង ដែលគំគួនឈ្នានិះសាស្ត្រាចារ្យនោះ ចាប់ខ្វាមពាក្យសំដីយកទៅបំផ្លើសមួលបង្កាច់ តើមានអ្វីធានាអះអាងចំពោះមុខរបរគ្នា ដែលជារបរនិយាយច្រើន? ដើម្បីឲ្យមានសុចរិតយុត្តិធម៌ គង់តែមានការអង្កេតត្រឹមត្រូវ កុំជឿសំដីមនុស្សម្នាក់ពីរនាក់ ។

ជាពិសេស សាស្ត្រាចារ្យចង់បានការធានាគ្រប់គ្រាន់ ចំពោះការផ្លាស់ចេញពីទីកន្លែងមិនសមហេតុមិនសមផល តាមតែនាយទៅហ្វាយចង់ « បំផ្លាង » ។

កិត្តិយសសាស្ត្រាចារ្យគឺ ឋានៈគេជាបណ្ឌិត ដឹងច្បាប់ទំលាប់ គេមិននិយមសេរីភាព ដើម្បីអានាធិបតេយ្យ គេគោរពវិន័យក្នុងមុខងារគេដោយថ្លៃថ្នូរ មិនគោរពដោយសារនាយទៅហ្វាយដាប់សំឡុត ឬ ដោយអែបអបនាយទៅហ្វាយ (par conformisme) ទេ ។ តាមការសង្កេត ការទាក់ទងសាស្ត្រាចារ្យជាមួយអភិបាលវិទ្យាល័យច្រើនតែទូលាយផង ហើយស្មើភាពផង ខាងគ្រូបង្រៀនទៅបឋមសិក្សា ។ នាយកសាលាមិនអាចបេះតែហៅសាស្ត្រាចារ្យ មកស្តីបន្ទោសកាច់ពត់តាមចិត្តទេ ។ សូម្បីតែចង់ដាំរៃដំរង់វិធីខាងគរុកោសល្យ នាយកគ្រាន់តែស្នើដោយលួចលាក់ រក្សាដម្លៃឲ្យសាស្ត្រាចារ្យជានិច្ច ហើយបើមានការពាស់ខុសខ្លាំង នាយកពិនិត្យពិច័យខ្លាំងណាស់មុននឹងហ៊ានហៅគេមកព្រមាន ។

នេះជាទិដ្ឋភាពមួយ នៃសិទ្ធិនិងកិត្តិយសសាស្ត្រាចារ្យដែលយើងត្រូវរក្សានិងការពារ ។

## អំពីភាគទាន

សូមមិត្ត-តំណាងក្នុងមណ្ឌលនិមួយៗ

ប្រមូលភាគទានឲ្យបានទៀងទាត់ ហើយផ្ញើមកគណៈកម្មាធិការនាយក ឲ្យបាន តាមកាលគួរផង ។

ចំពោះមិត្ត ដែលមិនទាន់បានទទួល

សន្លឹកឈ្មោះ នឹងបង្កាន់ដៃ ដែលគណៈកម្មាធិការកណ្ដាល ផ្ញើទៅក៏សូមជូន ដំណឹងឲ្យបានរួសរាន់ ។



## ទស្សនាវដ្ដីសាស្ត្រាចារ្យ

– មានផ្ញើលក់នៅ:

បណ្ណាគារ ប៊ុតឈាង

176 រុក្ខវិថីខេមរភូមិន្ទ ភ្នំពេញ

– បណ្ណាគារ សារវិត្តី

92 ជ្រុងវិថីព្រះច័ន្ទរាជា នឹងឧកញ៉ាឆ្នុង ភ្នំពេញ

តម្លៃ 12៛00